# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ( ម.ដ.ស. )

# នៅវិទ្យាល័យៈករណីសិក្សានៅខេត្តត្បូងឃ្មុំ

# Situation of School Operating Fund ( SOF ) Implementation in Upper Secondary School

## Case Study : Tbong Khmum Province


ដោយ/by

ពេជ្រ រង្សី/ PICH RANGSEY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩


ឧបត្ថមដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

## ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ( ម.ដ.ស. )

# នៅវិទ្យាល័យ៖ករណីសិក្សានៅខេត្តត្បូងឃ្មុំ

# Situation of School Operating Fund ( SOF ) Implementation in Upper Secondary School

## Case Study : Tbong Khmum Province

**ដោយ** / by

**ពេជ្រ រង្សី** / PICH RANGSEY

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧ - ២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖** ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

**សាស្ត្រាចារ្យដឹកនាំរង៖** លោក លុយ អេក

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៨៧២៩ **អយក.** [illegible]

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុធន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

នាងខ្ញុំ សូមប្រកាសអះអាងថា និក្ខេបបទ ដែលមានចំណងជើងថា ″ **ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ( ម.ដ.ស. ) នៅវិទ្យាល័យៈករណីសិក្សានៅខេត្តត្បូងឃ្មុំ** Situation of School Operating Fund ( SOF ) Implementation in Upper Secondary School: Case Study :Tbong Khmum Province សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនេះ គឺជាស្នាដៃសិក្សាស្រាវជ្រាវរបស់ខ្ញុំពិតប្រាកដមែន ។ ស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រ នៅវិទ្យាស្ថាន ឬសាកលវិទ្យាល័យណាមួយឡើយ ។ បន្ថែមលើនេះ រាល់សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទនេះ សុទ្ធតែបានចុះបញ្ជីក្នុងឯកសារយោងទាំងអស់ ។

និក្ខេបបទសិក្សាស្រាវជ្រាវខាងលើពិតជាត្រូវបានសិក្សា និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន ។

ថ្ងៃ......................ខែ..............ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី..............ខែ......................ឆ្នាំ ២០១៩

ហត្ថលេខាបេក្ខជន

**ពេជ្រ ខេរី**

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណារ៉ា** ជាសាស្ត្រាចារ្យដឹកនាំ
លោក **លុយ អោក** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោកស្រី ពេជ្រ រស្មី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀនក្នុងខេត្តត្បូងឃ្មុំ**" ពិតប្រាកដមែន។

ថ្ងៃ អង្គារ ១៤ កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ២០១៩

.......................................
**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណារ៉ា**
នាយកវិទ្យាស្ថានជាតិអប់រំ

.......................................
**លោក លុយ អោក**
សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ ពេជ្រ រង្សី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៧-២០១៩ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដោយបានបញ្ចប់ការស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ ។ លទ្ធផលដ៏ត្រចះត្រចង់នេះ នាងខ្ញុំ មិនភ្លេចចំពោះការជួយជ្រោមជ្រែងគាំទ្រ និងយកចិត្តទុកដាក់ពីសំណាក់មជ្ឈដ្ឋានជាច្រើន ។

ជាពិសេសសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មានឧបត្ថម្ភ និងផ្តល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។

សូមថ្លែងអំណរគុណគណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់រូបនាងខ្ញុំ ដោយមិនគិតពីការនឿយហត់។

ខ្ញុំសូមថ្លែងអំណរគុណឯកឧត្តមបណ្ឌិត សៀង សុវណ្ណា សាស្ត្រាចារ្យដឹកនាំ និងលោក លុយ អោក សាស្ត្រាចារ្យដឹកនាំរង ដែលបានណែនាំ និងឆ្លៀតពេលដ៏មានតម្លៃ ក្នុងការផ្តល់គំនិតណែនាំ ពុទ្ធិ និងទ្រឹស្តីល្អៗ ព្រមទាំងផ្តល់នូវកម្លាំងចិត្ត បញ្ញា ស្មារតី បច្ចេកទេស និងវិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ បានផ្តល់ឯកសារទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅដល់រូបនាងខ្ញុំរហូតដល់ការស្រាវជ្រាវរបស់ខ្ញុំ ទទួលបានជោគជ័យជាស្ថាពរ ។

សូមថ្លែងអំណរគុណចំពោះមិត្តរួមថ្នាក់ជំនាន់ទី៦ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបនាងខ្ញុំ តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យនាងខ្ញុំមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅ ។

សូមថ្លែងអំណរគុណចំពោះមន្ត្រីអប់រំនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ គ្រប់លំដាប់ថ្នាក់ នាយក នាយិកា លោកគ្រូ អ្នកគ្រូ តំណាងសហគមន៍តាមសាលាគោលដៅទាំងអស់ដែលបានចូលរួមសម្របសម្រួលឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការចុះប្រមូលទិន្នន័យធ្វើឱ្យការស្រាវជ្រាវ នេះទទួលបានជោគជ័យ។

ជាទីបញ្ចប់នាងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកប្រសិទ្ធពរ ជូនចំពោះ លោកអ្នកដ៏មានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន

និងកីឡា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការ CIESF ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យជាតិ និងអន្តរជាតិ ទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អ បរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

## មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡាជាក្រសួងមួយ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពក្នុងការធ្វើកំណែទម្រង់ការប្រឡងគ្រប់ប្រភេទ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក។ សាលារៀនជាផ្នែកមួយ ដ៏សំខាន់ក្នុងការផ្តល់សេវាសាធារណៈគ្រប់ជាន់ថ្នាក់ ហើយជាថ្នាលបណ្តុះនូវចំណេះដឹងដល់មនុស្សគ្រប់រូប គ្រប់វ័យ ដោយមិនរើសអើង និងប្រកាន់វណ្ណៈ ។ ដូចនេះដើម្បីឱ្យសាលារៀនមានការអភិវឌ្ឍ និងសម្រេចតាមគោលដៅអប់រំជាតិ ក៏ដូចជាគោលនយោបាយអប់រំផងនោះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យអនុវត្តនូវមូលនិធិដំណើរការសាលារៀន ( ម.ដ.ស. ឬ SOF ) នៅតាមគ្រឹះស្ថានសិក្សាសាធារណៈចាប់តាំងពីដើមឆ្នាំ២០១៩មកម្ល៉េះ ក្នុងគោលបំណងអភិវឌ្ឍន៍សាលារៀនប្រកបដោយចីរភាព ។ ដោយយល់ឃើញថាមូលនិធិដំណើរការសាលារៀនមានសារៈសំខាន់បែបនេះ អ្នកស្រាវជ្រាវបានជ្រើសរើសយកប្រធានបទស្តីពី "ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន(ម.ដ.ស. )នៅតាមវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ " មកធ្វើការសិក្សាស្រាវជ្រាវ ។

ការស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមវិទ្យាល័យចំនួនដប់ ក្នុងចំណោម វិទ្យាល័យទាំង ២៤ក្នុងខេត្តត្បូងឃ្មុំ ។ ការស្រាវជ្រាវពី "ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន" នៅតាមវិទ្យាល័យនានានេះមានគោលបំណងដើម្បីរកឱ្យឃើញនូវកត្តាដែលជំរុញឱ្យសាលាមាន ការអភិវឌ្ឍ និងបញ្ហាប្រឈមផ្សេងៗជាមួយនឹងដំណោះស្រាយនានា។ អ្នកសិក្សាស្រាវជ្រាវ បាន ប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យបឋមនៅតាមវិទ្យាល័យគោលដៅ ដោយផ្តល់ជូននាយកសាលា ១០ នាក់ នាយករង ២០នាក់ ប្រធានក្រុមបច្ចេកទេស ១៥៨ នាក់ សហគមន៍ ១៨នាក់ តំណាងគ្រូបង្រៀន២០នាក់ និងហិរញ្ញិក ១០នាក់ ។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី SPSS និង Excel ដោយវិភាគតាម Frequencies And Descriptive តាមរយៈការបង្ហាញជាតារាងស្ថិតិ និងដ្យាក្រាម ។ ការសិក្សាស្រាវជ្រាវ នេះបានរកឃើញថាការអនុវត្ត មូលនិធិដំណើរការសាលារៀនមានចំណុចខ្វះខាតច្រើនដូចជា ពុំសូវមានការចូលរួមពីអ្នកពាក់ព័ន្ធ ការអនុវត្តការងាររដ្ឋបាល និងបច្ចេកទេស ការរៀបចំផែនការថវិកា ការអនុវត្តចំណូល ចំណាយ ការទុកដាក់ឯកសារយោងសម្រាប់ពេលទូទាត់ ហើយមានវិទ្យាល័យខ្លះមានការអនុវត្តការងារនៅមានកម្រិតទាបនៅឡើយ ។ បញ្ហាប្រឈមទាំងនេះគឺបណ្តាលមកពីគុណវុឌ្ឍិបុគ្គល ធនធានចំណេះដឹងភាសាអង់គ្លេសនិងកុំព្យូទ័រ

នៅមានកម្រិតទាប ជំនាញរបស់គណៈកម្មការមូលនិធិដំណើរការសាលារៀននៅមានកម្រិត ថែមទាំងមិនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញគណនេយ្យ ភាពចាស់ទុំនៃការងារ និងការចុះពិនិត្យតាមដានរបស់ថ្នាក់ក្រោមជាតិនៅមានកម្រិតទាបជាដើម ។ ក្រៅពីនេះក៏មានបញ្ហាប្រឈមផ្សេងទៀតដែរដូចជាខ្វះបណ្តាញអគ្គិសនី បណ្តាញអ៊ីនធឺណិតយឺត និងការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងសាលា ក្នុងការជំរុញសិស្សឱ្យចូលរួមមតិយោបល់ក្នុងផែនការអភិវឌ្ឍន៍សាលារៀនជាដើម ។ តាមលទ្ធផលស្រាវជ្រាវបង្ហាញថាកត្តាដែលនាំឱ្យសាលារៀនមានការអភិវឌ្ឍគឺសាលាដែលមានការរៀបចំផែនការបានល្អ មានទំនាក់ទំនងល្អជាមួយសហគមន៍ ដៃគូអភិវឌ្ឍន៍ មាតាបិតាសិស្ស និងគុណភាពសិក្សារបស់សិស្ស ។

សរុបសេចក្តីមកស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ពិតជាជួបប្រទះនូវបញ្ហាស្មុគស្មាញដោយសារ នៅមានចំណុចខ្វះខាតជាច្រើនហើយចំណុចខ្វះខាតទាំងនោះ នឹងអាចមានផលប៉ះពាល់ដល់ស្ថានភាពនៃការដឹកនាំ និងគ្រប់គ្រងបុគ្គលិកអប់រំទាំងមូល ព្រមទាំងធ្វើឲ្យប៉ះពាល់ដល់គុណភាពនៃការអប់រំផងដែរ ។ អាស្រ័យហេតុនេះក្រសួងអប់រំ យុវជន និងកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាគួរតែបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងមូលនិធិដំណើរការសាលារៀននេះបន្ថែមទៀតពិសេសពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ឲ្យស្របតាមគុណវុឌ្ឍិ និងតាមសមត្ថភាពជំនាញ ។ សម្រាប់គ្រូបង្រៀនគួរបន្តពង្រឹងសមត្ថភាព ពង្រីកចំណេះដឹង មានទំនាក់ទំនងល្អជាមួយមិត្តរួមអាជីពឲ្យប្រសើរឡើង និងមានឆន្ទៈ មនសិកា ក្នុងការរួមចំណែកអភិវឌ្ឍន៍ជាតិឱ្យកាន់តែខ្លាំងទ្វេរឡើងទៀត ។

# Abstract

School Operating Fund (SOF) is a project to improve the Education Quality to reach the Education policy as NSDP ( National Strategy Development Plan ).Since 2019 Ministry Of Education Youths and Sport has implird the SOF in public school. In this research aims to explore and illustrate the challenges and best practice of Cambodian Upper Secondary School in Tbong Khmum Province and the reflection of the project. The sample that the researchers considered to be able reliable data was that 236persons of the SOF committee from 10 schools in deferent krong/ district in Tbong Khmum province was selected such as School priciple 10 persons Vice school principle 20 persons Team Leader Technical 158 persons Community18 persons Teller 10 persons Teacher's Representative 20 persons.

In this study, researchers used the instrument of questionnaire selection, consisting of 33-point questionnaire , divided into 3 parts : Part 1 General Situation Based ( with 7 point ranging from 1 to 7 ), Part 2 : Situation of School Operating Fund Based ( with 20 point ranging from 8 to 27 ) Part 3 : Challenges Solution and Request Based ( with 6 point ranging from 28 to 33 ), And Analysing by SPSS , Microsoft Excell , Tables and Charts .

The results of this research are as follows:

1) Limited of Stakeholders involved in School Opearting Fund Implementation high average of 2.14 (M = 2.14),
2) Community meeting for seeking new element high average of 2.27 (M=2.27)
3) Community meeting for identify priority needs element high average of 2.50 (M=2.50)

4) Level of Accounting Reporte high average of 2.41 (M=2.41)

5) Fund Dividing high average of 1.82 (M=1.82)

6) Monitoring and Evaluation Plan high average of 2.14 (M=2.14)

7) Reflection on Monitoring and Evaluation Plan high average of 1.88 (M=1.88)

8) Activities plan doesn´t reach the SOF project high average of 2.05 (M=2.05)

To sum up, the SOF implementation is not Management Experience ,Skill , Monitoring and Evaluating from DOE POE and there is also less training of SOF Book keeping,but High Commitment of Community and Stakeholder.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន.....i

លិខិតបញ្ជាក់.....ii

សេចក្តីថ្លែងអំណរគុណ.....iii-iv

មូលន័យសង្ខេប.....v-vi

Abstract.....vii-viii

បញ្ជីតារាង.....xii

បញ្ជីអក្សរកាត់.....xiii

ជំពូកទី១.....១

សេចក្តីផ្តើម.....២

១.១- លំនាំបញ្ហានៃការស្រាវជ្រាវ.....២-៣

១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ.....៣-៤

១.៣- គោលបំណងនៃការស្រាវជ្រាវ.....៤

១.៤- សំណួរស្រាវជ្រាវ.....៤-៥

១.៥- សារៈសំខាន់នៃការស្រាវជ្រាវ.....៥

១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.....៥

១.៦.១- វិសាលភាពនៃការស្រាវជ្រាវ.....៥

១.៦.២- ដែនកំណត់នៃការស្រាវជ្រាវ.....៥

១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ.....៥

ជំពូកទី២.....៦

រំលឹកទ្រឹស្តី.....៧

២.១- និយមន័យ.....៧

២.១.១- សាលារៀន.....៧-៨

២.១.២- មូលនិធិដំណើរការសាលារៀន.....៨

២.២- ប្រវត្តិមូលនិធិដំណើរការសាលារៀន.....៨-១០

២.៣- គោលការណ៍ផ្តល់មូលនិធិដំណើរការសាលារៀន.....១០

២.៤- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩.....១០-១១

២.៥- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ១១-១២
២.៦- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ១២-១៣
២.៧- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ១៣-១៧
២.៨- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ១៧-១៩
២.៩- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ១៩-២២
២.១០- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ២៣
២.១១- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ២៣-២៤
២.១២- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ២៤-២៥
២.១៣- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ២៦-២៧
២.១៤- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ២៧
២.១៥- ថវិកាជាក់ស្តែងដែលសាលាបានទទួលក្នុងឆ្នាំ២០១៩ ............ ២៧-២៨
ជំពូកទី៣ ............ ២៩
វិធីសាស្ត្រស្រាវជ្រាវ ............ ៣០
៣.១- ទីកន្លែងសិក្សាស្រាវជ្រាវ ............ ៣០
៣.២- ភាគសំណាក ............ ៣០-៣២
៣.៣- ឧបករណ៍ស្រាវជ្រាវ ............ ៣២
៣.៤- កម្រងសំណួរនិងគោលបំណងនៃកម្រងសំណួរ ............ ៣៣
៣.៥- ដំណើរការប្រមូលទិន្នន័យ ............ ៣៣
៣.៦- ការវិភាគទិន្នន័យ ............ ៣៣
៣.៧- ក្រមសីលធម៌នៃការស្រាវជ្រាវ ............ ៣៤
ជំពូកទី៤ ............ ៣៥
លទ្ធផលការស្រាវជ្រាវ ............ ៣៦
៤.១- លទ្ធផលការស្រាវជ្រាវ ............ ៣៦-៤៤
៤.២- សារៈសំខាន់នៃមូលនិធិដំណើរការសាលារៀន ............ ៤៤
៤.៣- បញ្ហាប្រឈមនិងដំណោះស្រាយនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ............ ៤៤
ជំពូកទី ៥ ............ ៤៥
សេចក្តីសន្និដ្ឋាន ការពិភាក្សា និងអនុសាសន៍ ............ ៤៦

៥.១- សេចក្តីសន្និដ្ឋាន ........................................................................................................៤៦
៥.២-សំណូមពរ ........................................................................................................ ៤៦-៤៧
ឯកសារយោង ........................................................................................................៤៨
ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា ..................................................៤៩
ឧបសម្ព័ន្ធទី ២៖ លិខិតឧទ្ទេសនាមរបស់វិទ្យាស្ថានជាតិអប់រំ .................................................. ៥០-៥១
ឧបសម្ព័ន្ធ ........................................................................................................ ៥២
ឧបសម្ព័ន្ធទី៣៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តត្បូងឃ្មុំ.................................... ៥២
ឧបសម្ព័ន្ធទី ៣៖ កម្រងសំណួរ ........................................................................................ ៥៣-៥៨
ឧបសម្ព័ន្ធទី ៤៖ ........................................................................................................៥៩
១-គណៈកម្មការមេប្រយោគ ........................................................................................................៥៩
២-គណៈកម្មការការពារនិក្ខេបបទ ........................................................................................................៦០
៣-គណៈកម្មការកណ្តាល ........................................................................................................៦១

## បញ្ជីក្រាហ្វិកនិងតារាង


តារាងទី១៖ បង្ហាញចំនួនសំណាកអ្នករងសម្ភាសតាមវិទ្យាល័យទាំង១០ ........................................ ៣១

តារាងទី២៖ បង្ហាញពីតួនាទី/មុខតំណែងអ្នករងសម្ភាស ............................................................ ៣១

តារាងទី៣៖ បង្ហាញកម្រិតវប្បធម៌ទូទៅអ្នករងសម្ភាសតាមវិទ្យាល័យទាំង១០.................................. ៣១

តារាងទី៤៖ បង្ហាញភាគរយនៃភេទអ្នករងសម្ភាសតាមវិទ្យាល័យទាំង១០...................................... ៣១

ក្រាហ្វិកទី៥៖ បង្ហាញពីភាគរយជំនាញឯកទេស/វិជ្ជាជីវ/មុខរបរអ្នករងសម្ភាស ..................................៣២

តារាងទី៦៖ បង្ហាញភាគរយបទពិសោធន៍ក្នុងវិស័យអប់រំរបស់អ្នករងសម្ភាស ........................... ៣២-៣៦

តារាងទី៧៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការចូលរួមរៀបចំផែនការថវិកា......... ៣៦-៣៧

តារាងទី៨៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការចូលរួមផ្តល់ធាតុចូលថ្មីៗ...................៣៧

តារាងទី៩៖ បង្ហាញចំនួនសំណាកអ្នករងសម្ភាសតាមវិទ្យាល័យទាំង១០ ........................................ ៣៨

តារាងទី១០៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការធ្វើរបាយការណ៍ .....................៣៨-៣៩

តារាងទី១១៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃកិច្ចបញ្ជីការគណនេយ្យ ................ ៣៩-៤០

តារាងទី១២៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃទូទាត់ចំណាយ .................................៤០

តារាងទី១៣៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការផ្តល់ឯកសារគាំទ្រសម្រាប់ការទូទាត់ ចំណាយ ........................................................................................................៤១

តារាងទី១៤៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃបែងចែកថវិកា ............................ ៤១-៤២

តារាងទី១៥៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃអនុវត្តផែនការចុះពិនិត្យតាមដានលើឯកសារ និងរបាយការណ៍មូលនិធិដំណើរការសាលារៀន ..................................................៤២-៤៣

តារាងទី១៦៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការប្រជុំឆ្លុះបញ្ចាំងកំហុសនិងវឌ្ឍនភាពបន្ទាប់ ពីចុះពិនិត្យតាមដាន......................................................................... ៤៣-៤៤

តារាងទី១៧៖ បង្ហាញមធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃបញ្ហាប្រឈមនឹងឯកសារទូទាត់ ការគ្រោង ថវិកា កំណត់សកម្មភាពអាទិភាព .......................................................................៤៤

# បញ្ជីអក្សរកាត់

១. វិ.ហស ច.ថ ៖ វិទ្យាល័យ ហ៊ុនសែនចារថ្មី
២. វិ.ហសត.ប ៖ វិទ្យាល័យ ហ៊ុនសែន តំបែរ
៣. វិ.សតហសសួង ៖ វិទ្យាល័យ សម្ដេចតេជោ ហ៊ុន សែន សួង
៤. វិ.ហស អូ.ឪ ៖ វិទ្យាល័យ ហ៊ុន សែន អូររាំងឪ
៥. វិ.ហស ព.ក ៖ វិទ្យាល័យ ហ៊ុន សែន ពញាក្រែក
៦. វិ. ក.ឆ ៖ វិទ្យាល័យក្រូចឆ្មារ
៧. វិ. ក ៖ វិទ្យាល័យក្រែក
៨. វិ.ស.ម ៖ វិទ្យាល័យសម្ដេចម៉ែ
៩. វិ.បនហស ម.ម ៖ វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់
១០. វិ.បនហសអ.ជ ៖ វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីក
១១. ម.ដ.ស. ៖មូលនិធិដំណើរការសាលារៀន
១២. SOF ៖ School Operating Fund
១៣. ផ.យ.អ.ជ ៖ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ
១៤. NSDP ៖National Strategy Development Plan
១៥. STEM ៖Science Technology Engineering Mathematic
១៦. អ.យ.ក.ហវ ៖នាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ យុវជន និងកីឡា
១៧. សហវ.អថ ៖អង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
១៨. សហវ.ប្រក ៖ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
១៩. SBM ៖ School Based Management
២០. គ.ស.ផ.ល ៖ការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

ការធ្វើសមាហរណកម្មទៅក្នុងសមាគមអាស៊ានឆ្នាំ២០១៥ និងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ទាមទារឱ្យមានការវិនិយោគបន្ថែមទៀតក្នុងវិស័យអប់រំ។ ដើម្បីសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំយុវជន និងកីឡា បានចាប់ផ្តើម ធ្វើកំណែទម្រង់វិស័យអប់រំ ដោយដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេល៥ឆ្នាំ និងផ្តោតសំខាន់ទៅលើការអភិវឌ្ឍធនធានមនុស្សដើម្បីធ្វើការប្រកួតប្រជែងក្នុងទីផ្សារ ពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហដោយពង្រឹងគុណភាពអប់រំ លើកកម្ពស់ការស្រាវជ្រាវ វិទ្យាសាស្រ្ត បច្ចេកទេស និងនវានុវត្តន៍ (ឯ.ឧបណ្ឌិត ហង់ជួន ណារ៉ុន, ២០១៤) ។

យុទ្ធសាស្ត្រចតុកោណ«ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០» ។ ក្នុងបរិការណ៍នេះ,រាជរដ្ឋាភិបាលយល់ឃើញថា យុទ្ធសាស្រ្តចតុកោណ ជាពិសេសគោលដៅសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សម្រាប់អនុវត្តនៅក្នុងនីតិកាលទី៦ឆ្នាំ ២០១៨-២០២៣ ត្រូវពង្រឹងបន្ថែមទៅលើសមិទ្ធផលសម្រេចបានកន្លងមកនិងផ្តោតសំខាន់លើរបៀបវារៈធានា« ប្រសិទ្ធភាព» តាម រយៈការអនុវត្តអភិក្រម « ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ » ( ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិឆ្នាំ២០១៩-២០២៣ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន ទំព័រទី១-២៤ ) ។

នៅក្នុងអាណត្តិទី៦នេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ។ ចំណែកក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ ស្តីពី « ការពង្រឹងគុណភាពអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា STEM» ដោយផ្តោតលើការយកចិត្តទុកដាក់លើគ្រូបង្រៀន និងនាយកសាលារៀន ដែលជាកត្តាគន្លឹះនាំឱ្យការអប់រំទទួលបានផលជាពលរដ្ឋដែលមានគុណភាព ។ ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព (SBM) នឹងនាំមកនូវលទ្ធផលសិក្សាល្អ ( គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ៥ តុលា ២០១៨ ) ។

ក្រៅពីនេះក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេល៥ឆ្នាំ ដោយផ្តោតសំខាន់ទៅលើគុណភាពគ្រូបង្រៀន ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ការងារអធិការកិច្ច ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ការអប់រំបំណិនស្របតាមទីផ្សារការងារ

ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយជាដើម។ ផែនការយុទ្ធសាស្រ្តនេះ នឹងជួយកសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុត លើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

សាលារៀន ជាគ្រឹះស្ថានសិក្សាដែលដើរតួយ៉ាងសំខាន់ ក្នុងការអនុវត្តដោយផ្ទាល់នូវរាល់កម្មវិធីកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅមូលដ្ឋានរបស់ខ្លួនឱ្យកាន់តែមានគុណភាពល្អប្រសើរ ។ ដោយមើលឃើញពីអត្ថប្រយោជន៍នេះដើម្បីឱ្យសាលារៀនមានដំណើរការសម្រេចនូវគោលនយោបាយអប់រំ ក៏ដូចជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាល នៅដើមឆ្នាំ ២០១៩ក្រសួងបានធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុអប់រំតាមគ្រឹះស្ថានសិក្សាសាធារណៈ ដោយបានទំលាក់ថវិកាដំណើរការសាលារៀន( ម.ដ.ស. ) ដល់សាលារៀនសាធារណៈដោយផ្ទាល់ ក្នុងន័យជាការវិភាជន៍ថវិកាឱ្យឆ្លើយតបទៅនឹងគោលដៅនយោបាយអប់រំ ស្វ័យភាពហិរញ្ញវត្ថុនិងគណនេយ្យភាពសាលារៀន ដោយមានសវនកម្មថវិកាអប់រំដែលគ្រប់គ្រឹះស្ថានទាំងអស់កំពុងតែអនុវត្ត ( យោងប្រកាស៥០៨សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំយុវជន និងកីឡា,ប្រកាស អន្តរក្រសួងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ៣៦៦សហវ.ប្រក មាន៦ជំពូក ១៩ ប្រការ ចុះថ្ងៃទី០៦/០៤/២០១៥ ,លិខិតលេខ ៣៤៣៦ អយក.ហវ ចុះថ្ងៃទី២៥/០៦/២០១៨ , លិខិតលេខ១០០៤ សហវ.អថ ចុះថ្ងៃទី២៥/១០/២០១៨ )។ ដោយមើលឃើញពីសារសំខាន់នេះទើបនាងខ្ញុំសម្រេចចិត្តលើកយកប្រធានបទដែលទាក់ទងនឹង « ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ »មកធ្វើជាប្រធានបទសម្រាប់ការស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រសួងក៏បានរៀបចំគោលនយោបាយគ្រូបង្រៀនដោយបានរៀបចំកំណែទម្រង់ធំៗរួមមាន កំណែទម្រង់ការគ្រប់គ្រងការសិក្សា កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សសម្រាប់រយៈពេល៥ឆ្នាំទៅមុខ ព្រោះនឹងជួយពង្រឹងគុណភាពវិស័យអប់រំឱ្យកាន់តែប្រសើរឡើង ការធ្វើទំនើបកម្មទៅលើកម្មវិធីសិក្សា និងពង្រឹងគុណភាពគ្រូបង្រៀនឲ្យមានសមត្ថភាពខ្ពស់ ឲ្យមានលក្ខណៈប្រហាក់ប្រហែលនឹងកម្មវិធីសិក្សានៅតាមបណ្តាប្រទេសជិតខាងគឺជារឿងចាំបាច់។

ជាងនេះទៅទៀត ត្រូវអភិវឌ្ឍន៍រោងជាងនៅតាមសាលាមួយចំនួនឲ្យទៅជាកន្លែងជួសជុលកុំព្យូទ័រ ឬអេឡិចត្រូនិកវិញ ដើម្បីឲ្យសិស្សមានជំនាញថ្មីៗមុនពេលបញ្ចប់ការសិក្សានៅកម្រិតវិទ្យាល័យ ឈានទៅបន្តការសិក្សានៅកម្រិតឧត្តមសិក្សា និងរៀបចំសោភ័ណភាព ឬបរិស្ថាន នៅតាមសាលារៀនឲ្យបានស្អាត ដើម្បី

ធ្វើយ៉ាងណាឲ្យសិស្សចូលចិត្តសាលានិងចង់រៀន(លោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និង កីឡា មានប្រសាសន៍កាលពីព្រឹកថ្ងៃទី០៨ ខែមករាឆ្នាំ២០១៩ ដោយ សំអឿន កាសែតរស្មីកម្ពុជា) ។ សព្វថ្ងៃ ក្រសួងអប់រំ យុវជន និងកីឡា កំពុងយកចិត្តទុកដាក់ធ្វើកំណែទម្រង់វិស័យអប់រំដើម្បីធ្វើឲ្យវិស័យនេះនៅកម្ពុជាមានការរីកចម្រើន និងមានសក្តានុពលទាំងនៅក្នុងតំបន់ និងនៅលើសកលលោក ។ ការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យា ល័យក្នុងខេត្តត្បូងឃ្មុំបានអនុវត្តជាទូទៅក្នុងខេត្ត ដែលមានវិទ្យាល័យទាំង ២៤ ហើយការអនុវត្តនៅមានកម្រិត ។តើស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀននៅតាមវិទ្យាល័យប្រព្រឹត្តទៅយ៉ាងដូចម្តេច និងជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ ?

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ពីរគឺ ៖

ក. ស្វែងយល់ពីកម្រិតនៃការអនុវត្តមូលនិធិដំណើរការសាលារៀន

ខ.ស្វែងយល់ពីបញ្ហាប្រឈមនៃការអនុវត្តមូលនិធិដំណើរការសាលារៀន

## ១.៤- សំណួរស្រាវជ្រាវ

អាស្រ័យដោយពេលវេលា ឯកសារដែលពាក់ព័ន្ធនឹងការស្រាវជ្រាវពិបាករក ធនធានមានកំណត់ និងដោយសារកង្វះលទ្ធភាពក្នុងការចុះប្រមូលទិន្នន័យឱ្យបានគ្រប់វិទ្យាល័យទូទាំងប្រទេស ដែលត្រូវការចំណាយច្រើន ដូចនេះការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតលើតែវិទ្យាល័យមួយចំនួនក្នុងខេត្តត្បូងឃ្មុំប៉ុណ្ណោះ។ ការស្រាវជ្រាវនេះ ផ្តោតទៅលើនាយក នាយករង ប្រធានក្រុមបច្ចេកទេស តំណាងគ្រូបង្រៀន ហិរញ្ញិក និង សហគមន៍ ដែលជាគណៈកម្មការមូលនិធិដំណើរការសាលារៀន។ ភាគសំណាក ជ្រើសរើសយកតែវិទ្យាល័យចំនួន១០ នៃក្រុង/ស្រុកចំនួន៧ ក្នុងខេត្តត្បូងឃ្មុំដើម្បីធ្វើការសិក្សាស្រាវជ្រាវដោយវិទ្យាល័យទាំងនោះមានការអនុវត្តប្រហាក់ប្រហែលគ្នា អាចធ្វើជាតំណាងនៃវិទ្យាល័យទូទាំងខេត្តបាន។ វិទ្យាល័យដែលបានចុះស្រាវជ្រាវនោះរួមមានវិទ្យាល័យសម្តេចតេជោហ៊ុនសែនសួង វិទ្យាល័យសម្តេចម៉ែ វិទ្យាល័យ ក្រែក វិទ្យាល័យ ហ៊ុនសែនពញាក្រែក វិទ្យាល័យហ៊ុនសែន អូរាំងឪ វិទ្យាល័យក្រូចឆ្មារ វិទ្យាល័យ ហ៊ុនសែនតំបែរ វិទ្យាល័យ ហ៊ុនសែន ចារថ្មី វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនមេមត់ និងវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក ។ ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងតាមរយៈការរៀបចំតាក់តែងកម្រងសំណួសម្រាប់បំពេញ និងសម្រាប់សម្ភាសគណៈកម្មការមូលនិធិដំណើរការសាលារៀន នៅតាមវិទ្យាល័យនីមួយៗ។ ការសម្ភាសផ្តោតលើសហគមន៍ ការដឹកនាំនិងគ្រប់គ្រង ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថានសាលារៀន ហិរញ្ញប្បទាន និងការគ្រប់គ្រងហិរញ្ញវត្ថុ។ ចំពោះចំនួនសំណាកដែលត្រូវចូលរួមបំពេញកម្រងសំណួររួមមាន នាយកសាលា១០ នាក់ ( ០១នាក់ក្នុងមួយសាលា) នាយករង ២០នាក់ ( ២នាក់ក្នុង១សាលា) ប្រធានក្រុមបច្ចេកទេស១៥៨ នាក់ ( ១៣-១៦នាក់ ក្នុង១សាលា ) តំណាងគ្រូបង្រៀន២០នាក់ (២នាក់ក្នុងមួយសាលា) សហគមន៍១៨ នាក់ ( ១-២នាក់ក្នុងសាលា ) និង ហិរញ្ញិក ២០នាក់ (២នាក់ ក្នុងមួយសាលា) ។ ការសិក្សាស្រាវជ្រាវនេះគឺ

ផ្តោតលើបីចំណុចគឺ(១)ការរៀបចំផែនការថវិកា (២)ការអនុវត្តចំណូលនិងចំណាយ និង(៣)ការ ពិនិត្យតាមដាននិងវាយតម្លៃនៃការអនុវត្តមូលនិធិដំណើរការសាលារៀនក្នុងឆ្នាំសិក្សា ២០១៨-២០១៩តែប៉ុណ្ណោះ ។

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

តាមការបង្ហាញខាងលើ ការស្រាវជ្រាវនេះមានសារៈសំខាន់ដូចតទៅៈ

១.បានដឹងពីគុណសម្បត្តិ និងគុណវិបត្តិនៃការអនុវត្តមូលនិធិដំណើរការសាលារៀន

២.ជាបទពិសោធសម្រាប់យកទៅផ្តល់ជាអនុសាសន៍ដល់សាលាដទៃទៀតដើម្បីយកទៅអនុវត្ត។

៣.ជាមូលដ្ឋានគ្រឹះសម្រាប់អ្នកធ្វើគោលនយោបាយសាលារៀនគិតគួរពិចារណាក្នុងការធ្វើអន្តរាគមន៍ផ្សេងៗ។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១- វិសាលភាពនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាអំពី "ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលានៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ" ដោយបង្ហាញអំពីរបៀបនៃអនុវត្ត លទ្ធផល បញ្ហាប្រឈមក្នុងការអនុវត្តកន្លងមក។

### ១.៦.២- ដែនកំណត់នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើទៅលើវិទ្យាល័យទាំង១០ ក្នុងខេត្តត្បូងឃ្មុំ ដោយជ្រើសរើសវិទ្យាល័យក្នុងក្រុង/ស្រុកទាំង៧ ។

## ១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូក រួមមានៈ

ជំពូកទី១ សេចក្តីផ្តើមៈ ក្នុងជំពូកនេះនឹងមានការលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ។

ជំពូកទី២ ការរំលឹកទ្រឹស្តីៈ រាល់ទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះ ត្រូវបានលើកឡើងដើម្បីធ្វើជាគំនិត និងឆ្លុះបញ្ចាំង ទៅនឹងការរកឃើញថ្មី នៅក្នុងស្នាដៃស្រាវជ្រាវនេះផងដែរ។

ជំពូកទី៣ វិធីសាស្រ្តស្រាវជ្រាវៈ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវវិធីសាស្រ្តប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូសំណាក ព្រមទាំងវិធីសាស្រ្តវិភាគទិន្នន័យដែលប្រមូលបាន ។

ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវៈ លទ្ធផលនៃការស្រាវជ្រាវ នឹងត្រូវបានយកមកបកស្រាយ និងពិភាក្សាយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញ នៅក្នុងស្ថានភាពជាក់ស្តែង របស់សាលារៀននីមួយៗ ។

ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរៈ នេះជាផ្នែកដែល ត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងលើកឡើងនូវសំណូមពរមួយចំនួនក្នុងគោលបំណងលើកកម្ពស់ការគ្រប់គ្រងការអនុវត្តមូលនិធិដំណើរការសាលារៀនឱ្យមានលក្ខណៈល្អប្រសើរឡើង។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២

## រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះអ្នកសិក្សាផ្តោតខ្លាំងទៅលើ និយមន័យពាក្យគន្លឹះដែលទាក់ទងទៅនឹងស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ ។ ពាក្យគន្លឹះសំខាន់ៗដែលអ្នកសិក្សានឹង យកមកពន្យល់បកស្រាយនោះរួមមាន៖ សាលារៀន និងមូលនិធិដំណើរការសាលារៀន ។

### ២.១- និយមន័យ

### ២.១.១- សាលារៀន

រាជរដ្ឋាភិបាលកម្ពុជាបានវិនិយោគជាច្រើនលើវិស័យអប់រំក្នុងគោលបំណងអភិវឌ្ឍន៍ធនធានមនុស្ស និងលើកកម្ពស់មូលធនបញ្ញានៅកម្ពុជាដែលជាកាលានុវត្តភាពក្នុងការប្រកួតប្រជែងសេដ្ឋកិច្ច ដើម្បីបង្កើនផលិតភាព លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននិងវិបុលភាពសង្គម ។ ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ ក្នុងការអភិវឌ្ឍធនធានមនុស្សឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ។ ដើម្បីសម្រេចគោលដៅនេះ នាយកសាលា និងគ្រូបង្រៀនត្រូវមានតួនាទីយ៉ាងសំខាន់ ក្នុងការពង្រឹងគុណភាពអប់រំ ។ ចំណែកសាលារៀន គឺជាអង្គភាពទទួលខុសត្រូវផ្ទាល់ក្នុងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់មូលដ្ឋាន ។

- សាលារៀនជាគ្រឹះស្ថានដែលបណ្តុះបណ្តាលអប់រំមនុស្សគ្រប់វ័យសិក្សាដោយមិនប្រកាន់ឋានៈ ពូជសាសន៍ ពណ៌សម្បុរ ដោយផ្តល់នូវការអប់រំ ដែលជាវិធីចាត់ចែងបណ្តុះបណ្តាលនិងបង្រៀនបណ្តាអ្នករៀន។ អប់រំជាការអនុវត្តនៃគុកោសល្យអង្គមួយនៃការស្រាវជ្រាវ ទ្រឹស្តីនិងភាពជាក់ស្តែងដែលទាក់ទងទៅនឹងការបង្រៀននិង រៀនលើមុខវិជ្ជាផ្សេងៗ ដូចជាចិត្តវិទ្យា, ទស្សនវិទ្យា, វិទ្យាសាស្ត្រកុំព្យូទ័រ, ភាសាវិទ្យា, ប្រសាទវិទ្យា, សង្គមវិទ្យា និងមនុស្សវិទ្យា។ ការសិក្សាចាត់ទុកជាផលិតផលឬ ដំណើរការ និងចាត់ទុកក្នុងន័យទូលាយ ឬ បច្ចេកន័យ នេះបើយោងទៅតាមទស្សនវិទូ លោកGeorge F.Kneller។ ក្នុងន័យទូលាយ ការសិក្សាសំដៅដល់សកម្មភាព ឬ បទពិសោធន៍ណាមួយដែលមានផលស្លាបនាចិត្តគំនិត អត្តចរិត ឬ សមត្ថភាពផ្លូវកាយរបស់មនុស្សម្នាក់ៗបាន ក្នុងបច្ចេកន័យ ការសិក្សា បានដល់ ដំណើរការដែលសង្គមបណ្តុះបណ្តាលចំណេះដឹង គុណតម្លៃ និង ទក្ខភាព(ជំនាញ)យ៉ាងល្អិតល្អន់ដែលមរតកវប្បធម៌របស់សង្គមនោះពូនសន្សំមកពីជំនាន់មួយ ទៅជំនាន់មួយតាមរយៈសាលារៀន សាលាសិក្សា មហាវិទ្យាល័យ និង វិទ្យាស្ថានដទៃៗទៀត ។

ឧទាហរណ៍នៃគោលបំណងរបស់សាលា គឺរួមបញ្ចូល ទាំងការរកហេតុផលដើម្បីអភិវឌ្ឍន៍ ហើយវិះរកមធ្យោបាយដើម្បីរស់នៅយូរឆ្នាំ ដូចជាអ្នកបង្កើតវិធីសាស្ត្រ ជាសិល្បសាស្ត្រ នៃការស្វែងរក វិធីសាស្ត្រនៃការដាំដុះ ហើយបង្កើតមុខរបរដើម្បីផ្លាស់ប្តូរគ្នាទៅវិញទៅមក ។ គោលបំណងរបស់សាលាគឺបង្រៀនមនុស្សឲ្យចេះពីរបៀបគិត ។ទស្សនវិស័យរបស់សាលារៀន គឺផ្តល់សេវាអប់រំឱ្យចំទិសដៅ។ សាលារៀនត្រូវឈរលើ

ទស្សនៈអ្នកទទួលផលនៃការប្រើប្រាស់សេវា ជាពិសេសលទ្ធផលចុងក្រោយ ។ ការផ្តល់ចំណេះដឹងដល់សិស្ស លទ្ធផលចុងក្រោយគឺការងារ ប្រាក់ចំណូលខ្ពស់ ហើយគេអាចក្លាយជាពលរដ្ឋល្អដែលអាចរស់នៅក្នុងសង្គមមួយប្រកបដោយវិបុលភាព ។




## ២.១.២.មូលនិធិដំណើរការសាលារៀន

មូលនិធិដំណើរការសាលារៀន ជាការផ្តល់ធនធានហិរញ្ញវត្ថុដល់សាលារៀន ដែលជាឧបករណ៍និងមធ្យោបាយដ៏មានសារៈសំខាន់ដើម្បីកសាងធនធានមនុស្សសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិប្រកបដោយសមធម៌ បង្កើនការអភិវឌ្ឍសាលារៀនសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព លើកទឹកចិត្តឱ្យមានការអនុវត្តចក្ខុវិស័យថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាពចំពោះ គោលនយោបាយសាលាកុមារមេត្រីរួមជាមួយ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ផ្តល់តួនាទីគន្លឹះដល់គ្រូបង្រៀន អាជ្ញាធរ សហគមន៍ មាតាបិតាសិស្ស និងសិស្សក្នុងការចូលរួមរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននិងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន លើកកម្ពស់គណនេយ្យភាពក្នុងការគ្រប់គ្រងនិងតាមដានការប្រើប្រាស់ធនធាន ដើម្បីធានាបានភាពត្រឹមត្រូវ តម្លាភាព សុវត្ថិភាព ភាពជឿទុកចិត្តបាន និងបើកទូលាយ ។

## ២.២.ប្រវត្តិនៃមូលនិធិដំណើរការសាលារៀន(ម.ដ.ស.)

វិស័យអប់រំជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ដូច្នេះនាយកសាលារៀន ត្រូវចាត់ទុកជាអ្នកមានសក្តានុពលជាកូនសោគន្លឹះដ៏សំខាន់ក្នុងការបង្កើនគុណភាពអប់រំ និងជាអ្នកកំណត់នូវចក្ខុវិស័យរបស់សាលារៀនក្នុងន័យនេះនាយកសាលារៀនត្រូវមានកិច្ចសហការដ៏ជិតស្និទ្ធជាមួយមាតាបិតា អាណាព្យាបាលសិស្ស សហគមន៍ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតក្នុងការប្រើប្រាស់ថវិកា ឱ្យមានតម្លាភាព សុចរិតភាព និងចំទិសដៅ តាមផែនការដែលនាយកសាលារៀនបានគ្រោងទុក ដើម្បីជួយអភិវឌ្ឍន៍ កែលម្អសោភ័ណភាពសាលា ការបង្រៀនរបស់គ្រូ និងការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលល្អប្រសើរជាទីបំផុត និងដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស មាតាបិតាសិស្ស សហគមន៍ ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ការគ្រប់គ្រងហិរញ្ញវត្ថុរបស់សាលារៀន គឺឆ្លើយតបទៅនឹងការធ្វើកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ការគ្រប់គ្រងហិរញ្ញវត្ថុជាផ្នែកមួយសំខាន់ ក្នុងការជួយគាំទ្រឱ្យសាលារៀនសម្រេចបាននូវផែនការអភិវឌ្ឍ និងធានាបាននូវការចូលរៀនរបស់កុមារ កើនឡើង ជាពិសេសការសិក្សាប្រកបដោយ

គុណភាព ដែលអាចឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចសង្គម និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យាទំនើប ។ ជាមួយគ្នានេះ ដើម្បីធានាឱ្យមានដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាលារៀនប្រកបដោយប្រសិទ្ធភាព សាលារៀនត្រូវរៀបចំឱ្យមានគណៈកម្មការគ្រប់គ្រងការអនុវត្តផែនការដោយមានការបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវច្បាស់លាស់ក្នុងការប្រើប្រាស់ថវិការបស់សាលារៀន ការចូលរួមសម្រេចចិត្ត និងមានការត្រួតពិនិត្យប្រកបដោយគុណភាពពីអ្នកពាក់ព័ន្ធ ។ លើសពីនេះទៀតការរៀបចំរចនាសម្ព័ន្ធនេះ គឺដើម្បីពង្រឹងប្រព័ន្ធធ្វើការងាររួមគ្នាក្នុងសាលារៀន និងសហគមន៍ ដែលអាចអនុវត្តបានទាំងគុណភាព និងប្រសិទ្ធភាពស្របទៅតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ។ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ បានរៀបចំផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៨ តាមទម្រង់អនុវិស័យក្នុងគោលបំណងបន្សុីគ្នារវាងថវិកា និងលទ្ធផលទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ផ្តល់សេវាសាធារណៈ ដែលជាដំណាក់កាលទី៣នៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ។ កំណែទម្រង់នៃការធ្វើផែនការតាមអនុវិស័យនេះ គឺតម្រូវឱ្យនាយកដ្ឋានដែលពាក់ព័ន្ធទាំងអស់ធ្វើផែនការអនុវត្តផែនការ ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តផែនការជាមួយគ្នា ។ ការធ្វើកិច្ចការជាមួយគ្នានេះមានគោលដៅតែមួយគឺការលើកកម្ពស់គុណភាពសេវាសាធារណៈឱ្យមានស្តង់ដាពេញលេញតាមស្តង់ដាសាលារៀនមានប្រសិទ្ធភាព និងស្របទៅតាមគោលនយោបាយសេវាសាធារណៈរបស់រាជរដ្ឋាភិបាល ។ ការផ្តល់ធនធានហិរញ្ញវត្ថុដល់សាលារៀន ជាឧបករណ៍និងជាមធ្យោបាយដ៏មានសារសំខាន់ដើម្បីកសាងធនធានមនុស្សសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមប្រកបដោយសមធម៌ ។ គោលការណ៍ណែនាំស្តីពី « ការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន » នឹងក្លាយជាឧបករណ៍សម្រាប់គ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈដ៏មានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ស្របតាមគោលការណ៍សុខុលអភិបាលកិច្ចល្អដើម្បីសិស្សានុសិស្សទទួលបានសេវាអប់រំ ប្រកបដោយគុណភាព និងសមធម៌ ។ នៅឆ្នាំ២០១៩ មូលនិធិដំណើរការសាលារៀន ( ម.ដ.ស.ឬSOF) ត្រូវបានដាក់ឱ្យអនុវត្តនៅតាមគ្រឹះស្ថានសិក្សាសាធារណៈតាមប្រកាស៥០៨សហវ.ប្រក និង៣៦៦ សហវ.ប្រក ។ មូលនិធិ ដំណើរការសាលារៀន(ម.ដ.ស.ឬSOF) មានប្រភពថវិកាផ្សេងៗពីគ្នា ។

១.ប្រភពថវិកាពីដៃគូគេហៅថា ម.ដ.ស. ឬSOB ទម្លាក់ដោយក្រសួងទៅសាលា ។ ថវិកានេះបានមកពីដៃគូអភិវឌ្ឍន៍មានដូចជា SWEDEN,UNICEF,WorlBankនិងADBជាដើម។

២.ប្រភពថវិការដ្ឋ គេហៅថា SOF ទម្លាក់ថវិកាដោយមន្ទីរអប់រំ យុវជន និងកីឡាខេត្តទៅដល់សាលាតាមរយៈគណនីសាលានីមួយៗ ។

៣.ថវិកាសហគមន៍ បានមកពីការកៀរគរធនធានសប្បុរសជន

៤.ផ្សេងៗ បានមកពីផាសុី និងចំណូលផ្សេងៗទៀត ។

មូលនិធិដំណើរការសាលារៀនពីមុនមានប្រភពមកពី SIG( ២០១៧)ហើយបានក្លាយជា SIF នៅឆ្នាំ ២០១៨ ។ នៅពេលគ្រោងថវិកាសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ គឺប្រើឈ្មោះ SOB&SIF ។ ក្រោយមកបានក្លាយជាមូលនិធិដំណើរការសាលារៀន (ម.ដ.ស.ឬSOF )ហើយចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ ២០១៩តាមគ្រឹះស្ថានសិក្សានីមួយៗ ក្នុងគោលបំណង៖

- ពង្រឹងសេវាអប់រំដល់ក្រុមសិស្សងាយរងគ្រោះ
- លើកកម្ពស់គុណភាពនៃការផ្តល់សេវាអប់រំ
- បង្កើនការចូលរៀន និងអត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិតសិក្សា

- កាត់បន្ថយអត្រាបោះបង់ និងត្រួតថ្នាក់ ពិសេសនៅគ្រឹះស្ថានមធ្យមសិក្សា
- កសាងសមត្ថភាពដឹកនាំ គ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងការចូលរួមរបស់អាជ្ញាធរ សហគមន៍ មាតាបិតា អាណាព្យាបាលសិស្ស និងគ្រប់ភាគីពាក់ព័ន្ធ។

## ២.៣គោលការណ៍ផ្តល់មូលនិធិដំណើរការសាលារៀនសាធារណៈ

មូលនិធិដំណើរការសាលារៀនសាធារណៈត្រូវផ្តល់ជូនជាប្រាក់រៀល និងត្រូវបែងចែកផ្អែកតាមឆ្នាំសារពើពន្ធ (ឆ្នាំថវិកា) ដែលមានរយៈពេល ១២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ។

### ២.៣.១. រូបមន្តនៃការរៀបចំថវិកា

១.ថវិការដ្ឋ ៖ ថវិការដ្ឋត្រូវផ្តល់ជូនតាមនិយាមដែលមានចែងក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា រណ៍ផ្តលលនិធិ ។

២.ថវិកាដៃគូ៖ ត្រូវរៀបចំរូបមន្តថវិកាដោយឡែក ឬយកតាមរូបមន្តថវិការដ្ឋ ដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

៣.ថវិកាសហគមន៍៖ ចូលរួមផ្តល់ថវិកាតាមរយៈការរៃអង្គាស បុណ្យផ្កាសាមគ្គី ការប្រកួតកីឡា ការប្រគំតន្ត្រី និងការសម្តែងសិល្បៈសប្បុរសធម៌ ។ល។

៤.ថវិកាផ្សេងៗ ៖ គ្រប់ចំណូលដែលបានពីប្រភពផ្សេងៗ ដូចជាការលក់ផលិតផលផ្សេងៗ ផលិតផលស្នាដៃសិស្ស ភាស៊ីផ្ញើកង់ ម៉ូតូ អាហារដ្ឋាន/តូបលក់ ចំណូលការប្រាក់ពីធនាគារ និងការជួលផ្សេងៗនៅក្នុងសាលារៀន ត្រូវបង់ចូលជាមូលនិធិដំណើរការសាលារៀនសាធារណៈ ។

### ២.៣.២ លក្ខណៈសម្បត្តិក្នុងការផ្តល់មូលនិធិដំណើរការសាលារៀនសាធារណៈ

ថវិកា ម.ដ.ស. នឹងផ្តល់ជូនសាលារៀនសាធារណៈ ដែលមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

១. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន
២. ផែនការយុទ្ធសាស្ត្រថវិកា
៣. ផែនការថវិកាប្រចាំឆ្នាំ
៤. ផែនការប្រតិបត្តិប្រចាំឆ្នាំ

សម្គាល់៖ ចំពោះផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនត្រូវសម្រេចដោយប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ រីឯផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវសម្រេចដោយប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ។

## ២.៤.ថវិកាជាក់ស្តែងដែលសាលាបានទទួលនៅឆ្នាំ២០១៩

| ល.រ | ឈ្មោះវិទ្យាល័យ | ស្រុក | ចំនួនសិស្ស | ស្រី | ថវិកាដែលទទួលបានដើមឆ្នាំ២០១៩ | តំបន់ |
|---|---|---|---|---|---|---|
| ១ | ប៊ុនរ៉ានី ហ៊ុនសែន អម្តនៃជំនីក | ក្រូចឆ្មារ | ៣១១នាក់ | ១៦៣ | ១៥.៧៨៧.០០០៛ | ១ |
| ២ | ក្រូចឆ្មារ | ក្រូចឆ្មារ | ៣៨៤នាក់ | ២២២ | ១៧.០២៨.០០០៛ | ១ |
| ៣ | ហ៊ុនសែន ចារថ្មី | តំបែរ | ៦១០នាក់ | ២៩៦ | ២០.៥០០.០០០៛ | ២ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | ហ៊ុនសែនតំបែរ | តំបែរ | ៨១៤នាក់ | ៣៥១ | ២២.៦៨៥.០០០៛ | ២ |
| ៥ | សម្តេចម៉ែ | ត្បូងឃ្មុំ | ៥៤៩ | ២៩៩ | ១៩,៨៣៣,០០០៛ | ១ |
| ៦ | សម្តេចតេជោ ហ៊ុនសែន សួង | សួង | ១៤៣១ | ៧២០ | ៣៤,៨២៧,០០០៛ | ១ |
| ៧ | ហ៊ុន សែន ពញាក្រែក | ពញាក្រែក | ៨៨៨ | ៥០០ | ២៥,៥៩៦,០០០៛ | ១ |
| ៨ | ក្រែក | ពញាក្រែក | ៨៤៥ | ៤៤៣ | ២៤,៨៦៥,០០០៛ | ១ |
| ៩ | ហ៊ុន សែន អូរាំងឪ | អូរាំងឪ | ៧៤៤ | ៤៤៦ | ២៣,១៤៨,០០០៛ | ១ |
| ១០ | ប៊ុនរ៉ានី ហ៊ុនសែន មេមត់ | មេមត់ | ១៦០១ | ៨៥៣ | ៣៧,៧១៧,០០០៛ | ១ |

កំណត់សម្គាល់៖ តំបន់ធម្មតា ( ១ ) តំបន់ឆ្ងាយដាច់ស្រយាល(២)

រូបមន្តនៃការគណនា ៖ ចំនួនសិស្សx១៧.០០០៛+២.០០០.០០០៛+៨.៥០០.០០០៛ ( តំបន់ធម្មតា )

៖ចំនួនសិស្ស x១៩.០០០៛+២.៥០០.០០០៛+៨.៥០០.០០០៛(តំបន់ឆ្ងាយ ឬដាច់ស្រយាល)

* ចំពោះការគ្រោងថវិកាប្រចាំឆ្នាំដែលបានមកពីថវិកាថេរ (ថវិកាគាំទ្រ ) និងអថេរ (សិស្សម្នាក់ៗ ) ត្រូវយកទៅវិភាជន៍តាមសកម្មភាពគោលទាំងពីរ (១. គាំទ្រកិច្ចដំណើរការ និង ២. កែលម្អគុណភាពអប់រំ) ដោយផ្តោតលើតម្រូវការជាក់ស្តែងរបស់សាលារៀនហើយដើម្បីបានមូលនិធិដំណើរការសាលារៀន គ្រប់គ្រឹះស្ថានទាំងអស់ត្រូវរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ផែនាករប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន ផែនការថវិកាប្រចាំឆ្នាំ។ ថវិកាទាំងនេះប្រើប្រាស់លើសម្ភារមូលដ្ឋាន ការកែលម្អបរិស្ថានសាលារៀននិងថ្នាក់រៀន ចំណាយទូទាត់ថាមពលអគ្គិសនីនិងទឹក និងចំណាយផ្សេងៗ ។ (អនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡាលេខ៥០៨សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ) ។

## ២.៥ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមូលនិធិដំណើរការសាលារៀនសាធារណៈ

ការផ្តល់ធនធានហិរញ្ញវត្ថុដល់សាលារៀន គឺជាឧបករណ៍និងមធ្យោបាយដ៏មានសារសំខាន់ដើម្បីកសាងធនធានមនុស្សសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិប្រកប ដោយសមធម៌ ។

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់មូលនិធិដំណើរការសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡាមានវិសាលភាពអនុវត្តនៅតាមសាលារៀនសាធារណៈរួមមាន សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ អគារធនធានក្នុងវិទ្យាល័យ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស។

ក្នុងការអនុវត្តមូលនិធិដំណើរការសាលារៀន (ម.ដ.ស.)ការគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្តោតលើ ៖

ក. ការរៀបចំផែនការថវិកា គឺជាកិច្ចដំណើរការនៃការកំណត់ពីតម្រូវការថវិកាដើម្បីអនុវត្តសកម្មភាព ឬគម្រោងមួយ ដោយត្រូវផលិតបានជាលទ្ធផល និងសមិទ្ធផលជាក់ស្តែង ។

ខ. ការវិភាជថវិកា គឺជាដំណើរការបែងចែកថវិកាទៅតាមសកម្មភាពជាក់លាក់ និងខ្ទង់ថវិកាដោយអនុលោមតាមកាលវិភាគនៃការអនុវត្តផែនការសកម្មភាពនីមួយៗ ។

គ. ការអនុវត្តចំណូល និងចំណាយ គឺជានីតិវិធីហិរញ្ញវត្ថុ និងគណនេយ្យសម្រាប់ប្រើប្រាស់ថវិកាឱ្យចំទិសដៅ និងមានប្រសិទ្ធភាព ។

ឃ. ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ គឺជាកិច្ចដំណើរការប្រមូលទិន្នន័យ វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សមិទ្ធកម្ម និងការអនុវត្តនីតិវិធី ដើម្បីកំណត់ទិសដៅបន្ត

## ២.៦ គោលការណ៍ហិរញ្ញវត្ថុ

គោលការណ៍ហិរញ្ញវត្ថុគឺជាប្រព័ន្ធគ្រប់គ្រងមូលនិធិដំណើរការសាលារៀន
សាធារណៈ ដែលត្រូវកំណត់ដូចខាងក្រោម៖

១.មុខងារ និងភារកិច្ចទទួលខុសត្រូវរបស់សមាជិក គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈនីមួយៗ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ និងណែនាំឱ្យបានយល់ពីមុខងារ ភារកិច្ចនិងការទទួលខុសត្រូវរបស់សមាជិកម្នាក់ៗ ។

២.រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន (៥ឆ្នាំ) ផែនការយុទ្ធសាស្ត្រថវិកា (៣ឆ្នាំ) ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ។

៣.សាលារៀនសាធារណៈ ត្រូវអនុវត្តទៅតាមសៀវភៅណែនាំប្រតិបត្តិ ស្តីពីការគ្រប់គ្រងតាមសាលារៀន (SBM) និងមុខសញ្ញាចំណាយរបស់គោលការណ៍ ម.ដ.ស.។

៤.មូលនិធិដំណើរការសាលារៀនសាធារណៈ ត្រូវផ្ទេរចូលគណនីសាលារៀនផ្ទាល់តាមរយៈប្រព័ន្ធធនាគារពីរដងក្នុងមួយឆ្នាំ ។

៥.ថវិកាដៃគូអភិវឌ្ឍន៍ត្រូវផ្ទេរចូលគណនីធនាគារសាលារៀនជាប្រាក់រៀលតាមរយៈប្រព័ន្ធធនាគារ។

៦.ថវិកាចំណូលពីសហគមន៍ សប្បុរសជន និងចំណូលផ្សេងៗរបស់សាលារៀន ត្រូវបង់ចូលក្នុងគណនីធនាគារសាលារៀនជាប្រាក់រៀលតាមរយៈប្រព័ន្ធធនាគារ ។

៧.សាច់ប្រាក់ដែលបានដាក់ចូល និងដកចេញពីធនាគារសម្រាប់មូលនិធិដំណើរការសាលារៀនសាធារណៈ ត្រូវកត់ត្រាចូលក្នុងបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ ។

៨.សាច់ប្រាក់ដែលបានដកពីធនាគារ និងចំណាយសម្រាប់មូលនិធិដំណើរការសាលារៀនសាធារណៈត្រូវកត់ត្រាចូលក្នុងបញ្ជីបេឡា ។

៩.រាល់ការដកសាច់ប្រាក់ពីធនាគារត្រូវមានលិខិតស្នើសុំដកសាច់ប្រាក់ និងមូលប្បទានប័ត្រ ។

១០.រាល់ការដកសាច់ប្រាក់ពីបេឡាត្រូវមានសំណើសុំចំណាយថវិកានិងប័ណ្ណចំណាយ ដោយភ្ជាប់ជាមួយឯកសារគាំទ្រ ។

១១.សាលារៀនត្រូវបញ្ជូនរបាយការណ៍ទូទាត់ចំណាយថវិកាសរុបច្បាប់ដើម(តាមជំពូក គណនីអនុគណនី ) នៅរៀងរាល់ដើមខែនៃត្រីមាសបន្ទាប់ ទៅការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី២០ ខែធ្នូ នៃឆ្នាំនីមួយៗ ។

១២.ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក/ខណ្ឌ ត្រូវប្រមូលតារាង របាយការណ៍ទូទាត់ចំណាយថវិកាពីសាលារៀន នៅតាមក្រុង/ស្រុក/ខណ្ឌ របស់ខ្លួន បន្ទាប់មករៀបចំ និងបូកសរុបជារបាយការណ៍ទូទាត់ថវិកា (តាមជំពូក គណនី អនុគណនី) រួចបញ្ជូននៅរៀងរាល់ដើមខែ នៃត្រីមាសបន្ទាប់ទៅមន្ទីរអប់រំ យុវជន និងកីឡា លើកលែងត្រីមាសទី៤ ដែលត្រូវបញ្ជូនឱ្យបានមុនថ្ងៃទី២៥ខែធ្នូ នៃឆ្នាំនីមួយៗ ។

១៣.មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវប្រមូលរបាយការណ៍ទូទាត់ចំណាយថវិកាពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ហើយរៀបចំ និងបូកសរុបជារបាយការណ៍ទូទាត់ថវិកា (តាមជំពូក គណនី អនុគណនី) បន្ទាប់មកត្រូវរៀបចំបោះផ្សាយអាណត្តិ និយ័តកម្មបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីពិនិត្យ និងចុះទិដ្ឋាការក្នុងនាមជាអភិបាលហិរញ្ញវត្ថុ មុននឹងបញ្ជូនទៅរតនាគាររាជធានី ខេត្ត នៅត្រីមាសនីមួយៗ លើកលែងត្រី មាសទី៤ ដែលត្រូវបញ្ជូនយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំនីមួយៗ ។

១៤.សាលារៀនត្រូវបញ្ជូនរបាយការណ៍ចំណាយថវិកាទៅការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក/ខណ្ឌ រៀងរាល់ត្រីមាសនីមួយៗ យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែ នៅដើមត្រីមាសបន្ទាប់នីមួយៗ ។

១៥.គ.ម.ស. ត្រូវរៀបចំរបាយការណ៍បច្ចុប្បន្នភាពព័ត៌មានហិរញ្ញវត្ថុ ហើយត្រូវបិទផ្សាយនៅក្នុងបរិវេណសាលារៀន និងទីកន្លែងសាធារណៈ ។

១៦.នៅពេលអនុវត្តថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈចប់តាមឆ្នាំនីមួយៗ ប្រសិនបើក្រោយការចំណាយមានសាច់ប្រាក់នៅសល់ ត្រូវអនុវត្តដូចខាងក្រោម៖

ក. ថវិការដ្ឋ ៖ ត្រូវបង់ចូលថវិការដ្ឋវិញ យ៉ាងយូរត្រឹមថ្ងៃទី២០ ខែធ្នូ តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ សាមី

ខ. ថវិកាដៃគូ សហគមន៍ និងចំណូលផ្សេងៗ ៖ ត្រូវលើកយកទៅអនុវត្តបន្តនៅឆ្នាំបន្ទាប់

១៧.រៀបចំទុកដាក់កិច្ចបញ្ជីការគណនេយ្យ និងឯកសារគាំទ្រផ្សេងៗ ឱ្យបានត្រឹមត្រូវនិងមានសុវត្ថិភាពក្នុងសាលារៀនសាមីសម្រាប់ជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយ។

## ២.៧.គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ(គ.ម.ស.)

### ១ មុខងារ

•គ្រប់គ្រងមូលនិធិដំណើរការសាលារៀន

•ទទួលខុសត្រូវក្នុងការអនុវត្តមូលនិធិដំណើរការសាលារៀនឱ្យមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព

•បង្កើតហឹបតម្លាភាព ដើម្បីទទួលបានព័ត៌មាន ឬពាក្យបណ្តឹងផ្សេងៗពីអ្នកពាក់ព័ន្ធ

•ទទួលថវិកាសម្រាប់ការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ និងទទួលខុសត្រូវក្នុងការគ្រប់គ្រងមូលនិធិ ដូចខាងក្រោម៖

ក. ត្រូវបើកគណនីធនាគារ (ករណីមិនទាន់មានគណនីធនាគារ) ក្នុងនាមជាសាលារៀន

សាធារណៈ

ខ. ត្រូវអនុវត្តថវិកាស្របតាមផែនការរបស់សាលារៀន

គ. ត្រូវរៀបចំរបាយការណ៍ទូទាត់ និងរបាយការណ៍ចំណាយថវិកា ផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ តាមពេលកំណត់ ។

ឃ.ត្រូវរៀបចំ និងរក្សាទុកនូវកិច្ចបញ្ជីការគណនេយ្យនិងឯកសារគាំទ្រផ្សេងៗឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាព

ង. ត្រូវផ្តល់ការគាំទ្រនិងសហការក្នុងដំណើរការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្ម

## ២ សមាសភាព ភារកិច្ច និងការទទួលខុសត្រូវ




សម្គាល់ ៖ ក្នុងករណីសាលារៀនសាធារណៈណាដែលមិនមានសមាសភាពគ្រប់តាមការកំណត់ខាងលើត្រូវអនុវត្តតាមការជាក់ស្តែង និងមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលា។

## ៣.មុខងារ និងតួនាទីក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

សមាសភាព គ.ម.ស. នីមួយៗ មានតួនាទីជាមូលដ្ឋានដូចខាងក្រោម៖

**ក. ប្រធាន**

- ដឹកនាំចាត់ចែង សម្របសម្រួលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ធានាការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងដំណើរការអភិវឌ្ឍន៍សាលារៀន
- ដឹកនាំការកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន
- ពិនិត្យ និងសម្រេចលើគម្រោងទិញសម្ភារៈ ជួសជុល សាងសង់និងសេវានានា
- ចុះហត្ថលេខាលើមូលប្បទានប័ត្រ
- ពិនិត្យ និងសម្រេចលើប័ណ្ណចំណូល (គំរូលេខ ១) សំណើសុំ

- ថវិកា (គំរូលេខ ២)    ប័ណ្ណចំណាយ (គំរូលេខ ៣)
- ពិនិត្យ និងឯកភាពលើបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ (គំរូ
- លេខ ៤) បញ្ជីបេឡា (គំរូលេខ ៥) របាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច
- (តារាងលេខ ២.១ក) តាមសកម្មភាព (តារាងលេខ ២.១ខ) និងរបាយការណ៍ទូទាត់ចំណាយ
- ថវិកា (តារាងលេខ ៣.១)
- ទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុជូន
- ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក/ខណ្ឌ  តាមពេលកំណត់
- ពិនិត្យតាមដាន និងផ្សព្វផ្សាយលទ្ធផលការងារជូនភាគីពាក់ព័ន្ធ
- ចូលរួមសហការក្នុងពេលដំណើរការអធិការកិច្ច និងសវនកម្ម

**ខ. អនុប្រធាន**

- ជួយការងារប្រធាន
- ចូលរួមកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន
- ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ចុះហត្ថលេខាលើមូលប្បទានប័ត្រនៅពេលមានការផ្ទេរសិទ្ធិជូនពីប្រធាន
- ពិនិត្យ និងចុះហត្ថលេខាលើប័ណ្ណចំណូល សំណើសុំចំណាយថវិកា និងប័ណ្ណចំណាយ
- ពិនិត្យ និងចុះហត្ថលេខាលើបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ បញ្ជីបេឡា របាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចតាមសកម្មភាព របាយការណ៍ទូទាត់ចំណាយថវិកា
- រៀបចំរបាយការណ៍បច្ចុប្បន្នភាពព័ត៌មានហិរញ្ញវត្ថុ (គំរូលេខ ៨) និងត្រូវបិទផ្សាយនៅក្នុងបរិវេណសាលារៀន និងបញ្ជូរព័ត៌មានដទៃទៀត
- រៀបចំហឹបតម្លាភាព និងដាក់តម្កល់នៅជាប់ខ្លោងទ្វារសាលារៀន
- តាមដានការអនុវត្តផែនការសកម្មភាពរបស់អ្នកអនុវត្តនីមួយៗ
- ពិនិត្យតាមដានការរៀបចំទុកដាក់ឯកសារឱ្យបានត្រឹមត្រូវ ។

**គ. ហេរញ្ញិក**

- ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ

- កត់ត្រាចូលបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ
- ត្រូវរៀបចំមូលប្បទានប័ត្រដកសាច់ប្រាក់ពីធនាគារដើម្បីដាក់ជូនប្រធានប្រធាន ពិនិត្យ និង សម្រេច
- បើកសាច់ប្រាក់ពីធនាគារ និងរក្សាសាច់ប្រាក់ទុកក្នុងទូដែកឱ្យមានសុវត្ថិភាព
- រៀបចំប័ណ្ណចំណូល និងប័ណ្ណចំណាយសម្រាប់ដាក់ជូនប្រធានពិនិត្យ និង សម្រេចតាមឋានានុក្រម
- បើកសាច់ប្រាក់ជូនអ្នកស្នើសុំផ្អែកតាមសំណើសុំចំណាយថវិកានិងប័ណ្ណចំណាយ ដែលបានឯកភាពពីប្រធាន
- កត់ត្រាគ្រប់ប្រតិបត្តិការហិរញ្ញវត្ថុចូលក្នុងបញ្ជីបេឡា
- រៀបចំរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច តាមសកម្មភាព និងរបាយការណ៍ទូទាត់ចំណាយថវិកា ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក/ខណ្ឌ តាមពេលកំណត់
- រៀបចំទុកដាក់កិច្ចបញ្ជិកាគណនេយ្យ និងឯកសារគាំទ្រផ្សេងៗឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពសម្រាប់ជាកម្មវត្ថុនៃការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្ម
- ផ្តល់ការគាំទ្រ និងសហការក្នុងដំណើរការពិនិត្យតាមដាន អធិការកិច្ច និងសវនកម្ម ។

**ឃ. សមាជិក**

**១. ប្រធានក្រុមបច្ចេកទេស និងតំណាងគ្រូបង្រៀន**

- ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- សម្របសម្រួល និងអញ្ជើញអ្នកពាក់ព័ន្ធ ដូចជា ក្រុមបច្ចេកទេស គ្រូបង្រៀន តំណាងអាជ្ញាធរ សហគមន៍ មាតាបិតាសិស្ស និងសិស្ស ចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- រៀបចំ និងណែនាំគ្រូបង្រៀន ព្រមទាំងអ្នកពាក់ព័ន្ធរៀបចំសំណើសុំចំណាយថវិកាសម្រាប់បម្រើសេចក្តីត្រូវការក្នុងដំណើរការរៀន និងបង្រៀន
- ចុះហត្ថលេខាលើមូលប្បទានប័ត្រ ពេលហោរញ្ញិក ផ្ទេរសិទ្ធិជូនដោយមានការឯកភាពពីប្រធាន គ.ម.ស
- ជួយផ្សព្វផ្សាយបន្តអំពីដំណើរការអភិវឌ្ឍន៍ និងសមិទ្ធផល សាលារៀន ដល់សហគមន៍ និង ភាគីពាក់ព័ន្ធ។

២. តំណាងសហគមន៍

- សម្របសម្រួលនិងចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ
- ចូលរួមកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន
- ជួយផ្សព្វផ្សាយការងារសាលារៀនដល់សហគមន៍
- បើកហឹបតម្លាភាព នៅមុខអង្គប្រជុំ និងអានជូនអង្គប្រជុំដើម្បីទទួលបានព័ត៌មានត្រឡប់ពីសហគមន៍ដើម្បីដោះស្រាយ
- តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់សាលារៀន
- តាមដានការបិទផ្សាយជាសាធារណៈលើលទ្ធផលអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ។

## ២.៨ ការរៀបចំថវិកា

### ១.ការរៀបចំថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (ម.ដ.ស.)

ការបែងចែកមូលនិធិដំណើរការសាលារៀនសាធារណៈ ត្រូវបានរៀបចំដោយផ្អែកតាមរូបមន្តរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។ រូបមន្តនៃការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ របស់សាលារៀនសាធារណៈត្រូវអនុលោមដូចមានចែងក្នុង ជំពូកទី២ ចំណុច IV ត្រង់ "៤.១. រូបមន្តនៃការរៀបចំថវិកា" ។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និង ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌត្រូវណែនាំ និងសម្របសម្រួលដល់ដំណើរការរៀបចំផែនការឱ្យបានទាន់ពេលកំណត់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តថវិកា ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនត្រូវចាប់ផ្តើមរៀបចំនៅសប្តាហ៍ទី១ក្នុងខែមករានៃឆ្នាំ និងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែកុម្ភៈនៃឆ្នាំ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននេះ ត្រូវរៀបចំ៥ឆ្នាំម្តង និងអាចធ្វើការ ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ

ផែនការយុទ្ធសាស្ត្រថវិកា (៣ឆ្នាំ)ត្រូវចាប់ផ្តើមរៀបចំនៅសប្តាហ៍ទី១ ក្នុងខែមីនា នៃឆ្នាំ និងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែមីនា នៃឆ្នាំ រួចការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ បញ្ជូនផែនការនេះទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត យ៉ាងយូរនៅសប្តាហ៍ទី២នៃខែបន្ទាប់ ។

ផែនការថវិកាប្រចាំឆ្នាំ ត្រូវចាប់ផ្តើមរៀបចំនៅសប្តាហ៍ទី១ ក្នុងខែឧសភា នៃឆ្នាំនិងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែឧសភា នៃឆ្នាំ រួចការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ត្រូវប្រមូល និងបូកសរុបបញ្ជូនផែនការនេះទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត យ៉ាងយូរនៅ សប្តាហ៍ទី២នៃខែបន្ទាប់ ផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវចាប់

ផ្ដើមរៀបចំនៅសប្ដាហ៍ទី១ ក្នុងខែឧសភានៃឆ្នាំ និងត្រូវផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ យ៉ាងយូរត្រឹមដំណាច់ខែឧសភានៃឆ្នាំ រួចការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ត្រូវប្រមូល និងបូកសរុបបញ្ជូនផែនការនេះ ទៅមន្ទីរអប់រំ យុវជន យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ត្រូវប្រមូល និងបូកសរុបបញ្ជូនផែនការនេះ ទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត យ៉ាងយូរត្រឹមនៅសប្ដាហ៍ទី២ នៃខែបន្ទាប់។

### ២. ក្របខ័ណ្ឌនៃការរៀបចំផែនការ




### ៣. គោលការណ៍សម្រាប់រៀបចំផែនការ និងថវិកា ម.ដ.ស.

គ.ម.ស. ត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ ផ្អែកតាមការវិភាគស្ថានភាពបច្ចុប្បន្ន និងការកំណត់ទិន្នន័យសូចនាករសំខាន់ៗ។

ដើម្បីរៀបចំផែនការបានល្អ ត្រូវមានចំណុចសំខាន់ៗមួយចំនួន ដែលត្រូវលើកយកមកពិភាក្សា វិភាគ និងវាយតម្លៃ សម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចដូចជា៖

- កំណត់សមាសភាពចូលរួមឱ្យបានច្បាស់លាស់ និងគ្រប់ភាគីពាក់ព័ន្ធ
- វិភាគស្ថានភាពអប់រំជាក់ស្ដែងនៅសាលារៀន
- កំណត់គម្រោង និងសកម្មភាពជាអាទិភាពទៅតាមថវិកាដែលមាន
- កំណត់សូចនាករសមិទ្ធផលជាប្រយោជន៍ដល់សាលារៀនសាធារណៈ
- សូចនាករសមិទ្ធផល និងសូចនាករអនុវត្ត ត្រូវច្បាស់លាស់ អាចវាស់វែងបាន អាចសម្រេចបានក្នុងរយៈពេលកំណត់ និងមានភាពប្រាកដនិយម ព្រមទាំងជាកម្មវត្ថុដែលអាចត្រួតពិនិត្យ និងវាយតម្លៃបាន
- តម្រូវការថវិកាសរុបប្រចាំឆ្នាំត្រូវស្ថិតក្នុងពិដានថវិកាដែលបានបែងចែកស្របតាមឆ្នាំនីមួយៗរបស់សាលារៀន

- ក្របខ័ណ្ឌរៀបចំផែនការ



៤. ការកៀរគរថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន

ដើម្បីជាជំនួយបន្ថែមដល់ដំណើរការអភិវឌ្ឍន៍សាលារៀន គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ត្រូវចេះកៀរគរថវិកាសម្រាប់បំពេញបន្ថែមតាមរយៈសកម្មភាពដូចខាងក្រោមៈ

- ការអង្គាសពីអតីតសិស្ស សប្បុរសជន សហគមន៍ អាជ្ញាធរ អង្គការ វិស័យឯកជន
- ធ្វើបុណ្យផ្កាសាមគ្គី
- ការលក់ផលិតផលផ្សេងៗ និងការលក់ផលិតផលស្នាដៃសិស្ស
- ការប្រគុំតន្ត្រី និងសម្តែងសិល្បៈសប្បុរសធម៌
- ភាស៊ីផ្ញើកង់ ម៉ូតូ អាហារដ្ឋាន តូបលក់ និងការជួលផ្សេងៗ

## ២.៩. ការអនុវត្តថវិកា

### ១.រំហូរថវិការដ្ឋ




### ២. ជំហាននៃការផ្ទេរថវិកា

#### ២.១ ថវិការដ្ឋ

ថវិការដ្ឋត្រូវផ្ទេរថវិកាជូនសាលារៀននីមួយៗ **ចំនួន ២ (ពីរ) លើកក្នុង១ឆ្នាំ** គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនានៃឆ្នាំ ដោយត្រូវអនុវត្តតាមគោលការណ៍ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា។

#### ២.២ ថវិកាដៃគូ

ត្រូវផ្ទេរជូនសាលារៀនសាធារណៈនីមួយៗ **ចំនួន ២ (ពីរ) លើកក្នុង១ឆ្នាំ** គឺលើកទី១ នៅដើមខែមករា និងលើកទី២ នៅដើមខែមិថុនានៃឆ្នាំ។

#### ២.៣ ថវិកាសហគមន៍ និងផ្សេងៗ

ក្រោយពីទទួលបានសាច់ប្រាក់ សាលារៀនត្រូវបង់ចូលគណនីធនាគារមូលនិធិ

ដំណើរការសាលារៀនសាធារណៈ មិនឱ្យលើសេ៥ថ្ងៃនៃថ្ងៃធ្វើការ។

### ៣. នីតិវិធីនៃការផ្តល់សាច់ប្រាក់

#### ៣.១ ថវិការដ្ឋ

ថវិកាសម្រាប់ការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ ត្រូវផ្តល់ជូនដោយអនុលោមតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា។

#### ៣.២ ថវិកាដៃគូ

ថវិការបស់ដៃគូអភិវឌ្ឍន៍សម្រាប់ការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ ត្រូវផ្តល់ដោយយន្តការគម្រោង ឬដៃគូអភិវឌ្ឍន៍ តាមរយៈការផ្ទេរសាច់ប្រាក់ចូលគណនីធនាគាររបស់សាលារៀនសាធារណៈនីមួយៗ ដោយផ្អែកតាមសំណើសុំថវិកាដែលបានអនុម័ត។

### ៤. របាយការណ៍ថវិកា និងការដកសាច់ប្រាក់ចំណាយ

| ល.រ | សកម្មភាព | ការអនុវត្ត | ឯកសាររក្សាទុក |
|---|---|---|---|
| | ក. ចំណូល | | |
| ១ | ដើម្បីទទួលបានមូលនិធិដំណើរការសាលារៀនសាធារណៈ | -ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន<br>-ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន<br>-ផែនការថវិកាប្រចាំឆ្នាំ | -ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន<br>-ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន<br>-ផែនការថវិកាប្រចាំឆ្នាំ |
| | ការទទួលមូលនិធិផ្សេងៗ | សាលារៀនសាធារណៈនីមួយៗត្រូវរៀបចំបង្កាន់ដៃទទួលប្រាក់ (សាលារៀនត្រូវបង្កើតទម្រង់ដោយខ្លួនឯង) រួចហេរញ្ញិកយកទៅបង់ចូលគណនីធនាគារ | -បង្កាន់ដៃបង់ប្រាក់(របស់សាលារៀន)<br>-ប័ណ្ណបង់ប្រាក់ (របស់ធនាគារ) |
| ២ | ពេលដាក់ឬដឹងថាសាច់ប្រាក់ចូលក្នុងធនាគារ កត់ត្រាចូលបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ<br>ពេលដកសាច់ប្រាក់ពីធនាគារកត់ត្រា៖<br>-ចូលបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ<br>-ចូលបញ្ជីបេឡាសាលារៀន | -ប្រកាសឥណទានធនាគារ<br>-ប័ណ្ណបើក/ដកសាច់ប្រាក់ ឬមូលប្បទានប័ត្រ ឬប្រកាសឥណពន្ធ (ធនាគារ)<br>-កត់ត្រាក្នុងប័ណ្ណចំណូល | -ប្រកាសឥណទានធនាគារ<br>-ប័ណ្ណបើក/ដកសាច់ប្រាក់ ឬមូលប្បទានប័ត្រ ឬប្រកាសឥណពន្ធ (ធនាគារ)<br>-ប័ណ្ណចំណូល |
| | ខ. ការចំណាយ | | |
| | ការដកសាច់ប្រាក់ពីបេឡាសាលារៀន | ត្រូវដកសាច់ប្រាក់ចំណាយតាមសកម្មភាពជាក់ស្តែង | |

| | | | |
|---|---|---|---|
| | ទិញសម្ភារៈទំនិញ សេវា និង សំណង់ | -រៀបចំសំណើសុំចំណាយ<br>-កត់ត្រាប័ណ្ណចំណាយ<br>-វិក្កយបត្រ /បង្កាន់ដៃបង់ប្រាក់ | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយមានចំណារឯកភាពពីប្រធានគ.ម.ស.<br>-វិក្កយបត្រ /បង្កាន់ដៃបង់ប្រាក់ |
| ៣ | ពេលដាក់ឬដឹងថាសាច់ប្រាក់ចូលក្នុងធនាគារ កត់ត្រាចូលបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ | -ប្រកាសឥណទានធនាគារ | -ប្រកាសឥណទានធនាគារ |
| ៤ | ពេលដកសាច់ប្រាក់ពីធនាគារ កត់ត្រាៈ<br>-ចូលបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ<br>-ចូលបញ្ជីបេឡាសាលារៀន | -ប័ណ្ណបើក/ដកសាច់ប្រាក់ ឬមូលប្បទានប័ត្រឬប្រកាសឥណពន្ធ(ធនាគារ)<br>-កត់ត្រាក្នុងប័ណ្ណចំណូល | -ប័ណ្ណបើក/ដកសាច់ប្រាក់ ឬមូលប្បទានប័ត្រ ឬប្រកាសឥណពន្ធ (ធនាគារ)<br>-ប័ណ្ណចំណូល |
| **ខ. ការចំណាយ** | | | |
| ១ | ការដកសាច់ប្រាក់ពីបេឡាសាលារៀន | ត្រូវដកសាច់ប្រាក់ចំណាយតាមសកម្មភាពជាក់ស្តែង | |
| ២ | ទិញសម្ភារៈទំនិញ សេវា និង សំណង់ | -រៀបចំសំណើសុំចំណាយ<br>-កត់ត្រាប័ណ្ណចំណាយ<br>-វិក្កយបត្រ /បង្កាន់ដៃបង់ប្រាក់ | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយមានចំណារឯកភាពពីប្រធាន គ.ម.ស.<br>-វិក្កយបត្រ /បង្កាន់ដៃបង់ប្រាក់ |
| ៣ | ការប្រជុំ | -របៀបវារៈប្រជុំ<br>-រៀបចំសំណើសុំចំណាយ<br>-កត់ត្រាប័ណ្ណចំណាយ -វិក្កយបត្រ<br>-បញ្ជីវត្តមាន និងកំណត់ហេតុ ឬ របាយការណ៍ | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយមានចំណារឯកភាពពីប្រធាន គ.ម.ស -វិក្កយបត្រ<br>-បញ្ជីវត្តមាន របៀបវារៈប្រជុំ កំណត់ហេតុ ឬរបាយការណ៍ |
| ៤ | ការពិនិត្យតាមដាន និងបង្ការសិស្សបោះបង់ | -ផែនការពិនិត្យតាមដាន<br>-រៀបចំសំណើសុំចំណាយ<br>-កត់ត្រាប័ណ្ណចំណាយ<br>-វិក្កយបត្រ<br>-តារាងបើកប្រាក់ឧបត្ថម្ភ (បើអ្នកទទួលលើសពី ០១ នាក់)<br>-លិខិតឧទ្ទេសនាម | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយមានចំណារឯកភាពពីប្រធាន គ.ម.ស<br>-វិក្កយបត្រ<br>-តារាងបើកប្រាក់ឧបត្ថម្ភ<br>-លិខិតឧទ្ទេសនាម<br>-របាយការណ៍លទ្ធផល |

| | | | |
|---|---|---|---|
| | | -របាយការណ៍លទ្ធផល | |
| ៥ | មិត្តអប់រំមិត្ត | ផែនការ រៀបចំសំណើសុំចំណាយ កត់ត្រាប័ណ្ណចំណាយ វិក្កយបត្រ បញ្ជីវត្តមាន របាយការណ៍លទ្ធផល | ប័ណ្ណចំណាយ សំណើសុំចំណាយមានចំណារឯកភាពពីប្រធាន គ.ម.ស វិក្កយបត្រ បញ្ជីវត្តមាន របាយការណ៍លទ្ធផល |
| ៦ | ការបំប៉នឬសិក្ខាសាលា | -ផែនការ -រៀបចំសំណើសុំចំណាយ -កត់ត្រាប័ណ្ណចំណាយ -វិក្កយបត្រ -តារាងបើកប្រាក់ឧបត្ថម្ភ (បើអ្នកទទួលលើសពី ០១ នាក់) -របាយការណ៍លទ្ធផល | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយមានចំណារ ឯកភាពពីប្រធាន គ.ម.ស<br>-វិក្កយបត្រ-តារាងបើកប្រាក់ឧបត្ថម្ភ<br>-របាយការណ៍លទ្ធផល |
| ៧ | ការសិក្សាស្រាវជ្រាវ | -ផែនការ -រៀបចំសំណើសុំចំណាយ<br>-កត់ត្រាប័ណ្ណចំណាយ -វិក្កយបត្រ<br>-របាយការណ៍លទ្ធផល | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយមានចំណារ ឯកភាពពីប្រធាន គ.ម.ស<br>-វិក្កយបត្រ -របាយការណ៍លទ្ធផល |
| ៨ | ការចំណាយទិញសម្ភារៈទំនិញ សេវា និងសំណង់ លើសពី ៥ លានរៀលឡើង | -ទម្រង់សាកសួរតម្លៃចំនួន ០៣សន្លឹក (ពីអ្នកផ្គត់ផ្គង់ខុសគ្នា)<br>-តារាងវាយតម្លៃ<br>-កំណត់ហេតុប្រគល់-ទទួល<br>-វិក្កយបត្រ<br>-រៀបចំសំណើសុំចំណាយ<br>-រៀបចំប័ណ្ណចំណាយ | -ប័ណ្ណចំណាយ<br>-សំណើសុំចំណាយ<br>-កំណត់ហេតុប្រគល់-ទទួល<br>-វិក្កយបត្រ<br>-ទម្រង់សាកសួរតម្លៃចំនួន ០៣សន្លឹក (ពីអ្នកផ្គត់ផ្គង់ខុសគ្នា)<br>-តារាងវាយតម្លៃ |

## ៥. វិហរូវនៃការចំណាយថវិកា



## ២.១០. ការគ្រប់គ្រងគណនីធនាគារ

១. ថវិកាដែលត្រូវផ្ញើនៅគណនីធនាគាររបស់សាលារៀនរួមមាន៖

ក. ថវិការដ្ឋ

ខ. ថវិកាដៃគូ

គ. ថវិកាសហគមន៍

ឃ. ថវិកាផ្សេងៗ

២. សិទ្ធិចុះហត្ថលេខា និងសម្រេចលើគណនីធនាគារ

-ម្ចាស់គណនីធនាគារ ឬអ្នកមានសិទ្ធិ ចំនួន ៤នាក់ ដែលមាន៖

•ប្រភេទ A៖ ប្រធាន និងអនុប្រធាន (សរុប២នាក់)

•ប្រភេទ B៖ ហិរញ្ញិកនិងសមាជិក (សរុប២នាក់)

សម្គាល់៖ ក្នុងករណីសាលារៀនសាធារណៈណា មិនមានសមាសភាពគ្រប់ តាមការកំណត់ខាងលើត្រូវអនុវត្តតាមការជាក់ស្តែង និងមានការឯកភាពពីគណៈកម្មការគ្រប់គ្រងសាលា ។

-មូលប្បទានប័ត្រដកសាច់ប្រាក់ពីធនាគារ ត្រូវចុះហត្ថលេខាដោយអ្នកមានសិទ្ធិចំនួន ០២ រូប៖

•ករណីទី១៖ ត្រូវមានហត្ថលេខា ប្រភេទ A ១រូប (ប្រធាន ឬ អនុប្រធាន ១រូប) និង ប្រភេទ B ១រូប (ហេរញ្ញិក ឬ សមាជិក ១រូប)

•ករណីទី២៖ ត្រូវមានហត្ថលេខា ប្រភេទ A ២រូប (ប្រធាន និង អនុប្រធាន) ឬ ប្រភេទB ២ រូប(ហេរញ្ញិក និង សមាជិក)អនុវត្តតែក្នុងករណីអវត្តមានប្រភេទណាមួយទាំងពីរ ។

## ២.១១. ការពិនិត្យតាមដាន

យន្តការពិនិត្យតាមដានឱ្យមានប្រសិទ្ធភាពត្រូវបានបែងចែកដូចខាងក្រោម៖

**១. កម្រិតសាលារៀនសាធារណៈ**

នាយកសាលា គ្រូបង្រៀន សហគមន៍ និងភាគីពាក់ព័ន្ធ ត្រូវចូលរួមពិនិត្យតាមដាន ដូចជាការទទួលបានប្រាក់ចំណូល ការចំណាយ លទ្ធផលនៃការអនុវត្តសកម្មភាព ដូចជាការប្រជុំ ការពិនិត្យវឌ្ឍនភាពជាក់ស្តែងតាមសកម្មភាពនីមួយៗ ឬ ប្រើឧបករណ៍ពិនិត្យតាមដានដែលអាចឆ្លុះបញ្ចាំងពីដំណើរវឌ្ឍនភាពនៅតាមសាលារៀនសាធារណៈ ។

**២. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ**

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ត្រូវមានផែនការពិនិត្យតាមដានលើវឌ្ឍនភាពសេវាអប់រំនៅតាមសាលារៀនសាធារណៈនីមួយៗ។ ដូច្នេះ ដើម្បីធានានូវប្រសិទ្ធភាព ត្រូវមានឧបករណ៍ពិនិត្យតាមដាន សម្រាប់ប្រើប្រាស់ក្នុងពេលពិនិត្យតាមដាន។ រាល់ពេលចុះពិនិត្យតាមដាន ត្រូវមានរបាយការណ៍សម្រាប់តម្កល់ទុកជាមូលដ្ឋានកែលម្អ និងបូកសរុបតាមត្រីមាសនីមួយៗ ។

**៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានផែនការពិនិត្យតាមដានលើវឌ្ឍនភាពសេវាអប់រំនៅតាមសាលារៀនសាធារណៈនីមួយៗ។ ដូច្នេះ ដើម្បីធានានូវប្រសិទ្ធភាព ត្រូវមានឧបករណ៍ពិនិត្យតាមដានសម្រាប់ប្រើប្រាស់ក្នុងពេលពិនិត្យតាមដាន វាស់វែងកម្រិតវឌ្ឍនភាពនៃការផ្តល់សេវាអប់រំ។ រាល់ពេលចុះពិនិត្យតាមដាន ត្រូវមានរបាយការណ៍សម្រាប់តម្កល់ទុកជាមូលដ្ឋានកែលម្អ និងបូកសរុបតាមត្រីមាសនីមួយៗ។ ក្រោយបំពេញបេសកកម្មចប់ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវណែនាំបន្តដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ សម្រាប់ជាមូលដ្ឋានណែនាំបន្តដល់សាលារៀន។

**៤. ក្រសួងអប់រំ យុវជន និងកីឡា**

ក្រសួងអប់រំ យុវជន និងកីឡា ក្នុងដំណើរការពិនិត្យលើវឌ្ឍនភាពនៃការផ្តល់សេវាអប់រំនៅតាមសាលារៀនសាធារណៈនីមួយៗ ត្រូវមានឧបករណ៍ពិនិត្យតាមដានសម្រាប់ប្រើប្រាស់ក្នុងការវាស់វែងកម្រិតវឌ្ឍនភាពនៃការផ្តល់សេវាអប់រំ។ រាល់ពេលចុះពិនិត្យតាមដាន ត្រូវមានរបាយការណ៍សម្រាប់តម្កល់ទុកជាមូលដ្ឋានកែលម្អ និងបូកសរុបតាមត្រីមាសនីមួយៗ។ ក្រោយបំពេញបេសកកម្មចប់ ក្រសួងអប់រំ យុវជន និងកីឡាត្រូវណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ហើយមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវណែនាំបន្តដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ សម្រាប់ជាមូលដ្ឋានណែនាំបន្តដល់សាលារៀន។

## ២.១២. ប្រព័ន្ធរបាយការណ៍

សាលារៀនសាធារណៈនីមួយៗ ត្រូវរៀបចំ និងផ្ញើរបាយការណ៍ហិរញ្ញវត្ថុ ដូចខាងក្រោម ៖

**១. របាយការណ៍ចំណាយថវិកា**

របាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (តារាងលេខ ២.១ក) និងតាមសកម្មភាព (តារាងលេខ ២.១ខ) គឺជារបាយការណ៍ហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការរបស់សាលារៀនសាធារណៈប្រចាំត្រីមាស និងជារបាយការណ៍ជម្រះបញ្ជីសម្រាប់ថវិកាដែលបានទទួល ។ កាលបរិច្ឆេទនៃការផ្ញើរបាយការណ៍ចំណាយថវិកាមានដូចខាងក្រោម៖

-សាលារៀនសាធារណៈត្រូវរៀបចំរបាយការណ៍ចំណាយថវិកាផ្ញើជូនការិយាល័យអប់រំយុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ តាមត្រីមាស យ៉ាងយូរត្រឹមថ្ងៃទី៧ នៃខែបន្ទាប់

-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ត្រូវពិនិត្យរបាយការណ៍ចំណាយថវិកា និងបូក សរុបរួចត្រូវផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត យ៉ាងយូរត្រឹមថ្ងៃទី១០ បន្ទាប់ពីដំណាច់ ត្រីមាសនីមួយៗ

-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិនិត្យរបាយការណ៍ចំណាយថវិកា និងបូកសរុបរួចត្រូវផ្ញើ ជូនក្រសួងអប់រំ យុវជន និងកីឡា យ៉ាងយូរត្រឹមថ្ងៃទី២០ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។

**២. របាយការណ៍ទូទាត់**

**របាយការណ៍ទូទាត់ (តារាងលេខ ៣.១)** គឺជារបាយការណ៍នៃកិច្ចប្រតិបត្តិការ ថវិការដ្ឋរបស់សាលារៀនសាធារណៈ ប្រចាំត្រីមាសសម្រាប់ជម្រះបញ្ជីចំពោះថវិកាដែលបានទទួល។ កាលបរិច្ឆេទនៃការផ្ញើរបាយការណ៍ទូទាត់មានដូចខាងក្រោម៖

-សាលារៀនសាធារណៈត្រូវរៀបចំរបាយការណ៍ទូទាត់ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ ស្រុក/ខណ្ឌតាមត្រីមាស យ៉ាងយូរបំផុតត្រឹមថ្ងៃទី៥ នៃខែនៅដើមត្រីមាសបន្ទាប់

-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ ត្រូវពិនិត្យនិងបូកសរុបរបាយការណ៍ទូទាត់ រួចត្រូវផ្ញើជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ នៃខែនៅដើមត្រីមាសបន្ទាប់

-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិនិត្យ និងបូកសរុបរបាយការណ៍ទូទាត់ រួចបោះផ្សាយ អាណត្តិនិយ័តកម្ម បន្ទាប់មកត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុជូនក្រសួងអប់រំ យុវជន និងកីឡាយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែនៅដើមត្រីមាសបន្ទាប់។

**៣. របាយការណ៍សមិទ្ធកម្ម**

-ដើម្បីជាភស្តុតាងលើការអនុវត្តថវិកាដែលបានផ្តល់ជូន សាលារៀនសាធារណៈនីមួយៗ ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ យ៉ាងយូរត្រឹមថ្ងៃទី១០ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ

-មន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវពិនិត្យរបាយការណ៍សមិទ្ធកម្ម និងបូកសរុបរួចត្រូវផ្ញើជូនក្រសួងអប់រំ យុវជន និងកីឡា យ៉ាងយូរត្រឹមថ្ងៃទី២០ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ។

**៤. ឯកសាររបាយការណ៍ហិរញ្ញវត្ថុ**

សាលារៀនសាធារណៈត្រូវមានបញ្ជីឯកសារគាំទ្រសម្រាប់ប្រភេទរបាយការណ៍ផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌមានដូចខាងក្រោម៖

| ល.រ | បរិយាយ | ឯកសារគាំទ្រ |
|---|---|---|
| ១ | របាយការណ៍ចំណាយថវិកា | - តារាងលេខ ២.១ក<br>- តារាងលេខ ២.១ខ |
| ២ | របាយការណ៍ទូទាត់ | - តារាងលេខ ៣.១ |
| ៣ | របាយការណ៍សមិទ្ធកម្ម | - របាយការណ៍សមិទ្ធកម្ម |

## ២.១៣. ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

**១.យន្តការត្រួតពិនិត្យផ្ទៃក្នុង**

នៅក្នុងនីតិវិធីអនុវត្តថវិកា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដើម្បីធានាថាថវិកាត្រូវបានប្រើប្រាស់ក្នុងគោលបំណងរួមរបស់សាលារៀនសាធារណៈនីមួយៗ ។ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងគឺជាគន្លងនៃវិធានច្បាប់គោលការណ៍និងនីតិវិធីផ្សេងៗរបស់អង្គភាពសម្រាប់អនុវត្តដើម្បីធានាថា៖

១). ដំណើរការប្រតិបត្តិការមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព

២). ការអនុវត្តសកម្មភាពត្រឹមត្រូវស្របតាមវិធានច្បាប់ និងលិខិតគតិយុត្តផ្សេងៗ

៣). របាយការណ៍ហិរញ្ញវត្ថុត្រឹមត្រូវអាចជឿទុកចិត្តបាន ។

ដើម្បីធានាបានការសម្រេចគោលបំណងនិងគោលដៅក្នុងការអភិវឌ្ឍសាលារៀនសាធារណៈ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តដូចខាងក្រោម ៖

-ការសម្រេចបាននូវចក្ខុវិស័យ បេសកកម្មរបស់សាលារៀន

-ការត្រួតពិនិត្យលើកម្រិតនៃការបំពេញការងារ

-គណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈនិងគ្រប់ភាគីពាក់ព័ន្ធត្រូវអនុវត្តតាមមុខងារ និងភារកិច្ចរបស់ខ្លួន ដើម្បីធានាថាសិស្សបានទទួលសេវាអប់រំល្អប្រសើរ

-កំណត់ត្រាគណនេយ្យ និងសម្ភារៈត្រូវកត់ត្រាជាប្រចាំទៅតាមប្រតិបត្តិការហិរញ្ញវត្ថុដែលកើតឡើងចៀសវាងការទុកចោល ឬកត់ត្រាមួយខែម្តង ឬមួយត្រីមាសម្តង

-ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ត្រូវធានាថា ការបំពេញមុខងាររបស់សាលារៀនស្របតាមវិធានច្បាប់ និងនីតិវិធីនានាដូចមានចែងក្នុងគោលការណ៍ណែនាំនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតដែលមានជាធរមាន

-ការព្យាករហានិភ័យនានា ការបង្ការទុកជាមុន ដើម្បីឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពខ្ពស់។

**២.ការធ្វើសវនកម្ម**

**១. សវនកម្មផ្ទៃក្នុង**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងគឺជាអង្គភាពចំណុះឱ្យក្រសួងអប់រំ យុវជន និងកីឡា និងជាសេនាធិការផ្ទាល់របស់រដ្ឋមន្ត្រីមានភារកិច្ចធ្វើសវនកម្មប្រចាំឆ្នាំនីមួយៗលើសាលារៀនសាធារណៈទាំងអស់ ។

**២. សវនកម្មឯករាជ្យ**

ស្ថាប័នរដ្ឋ និងក្រុមហ៊ុនសវនកម្មឯករាជ្យអាចនឹងធ្វើសវនកម្មប្រចាំឆ្នាំនីមួយៗលើសាលារៀនសាធារណៈ ដើម្បីធានាភាពត្រឹមត្រូវ និងតម្លាភាពទ្វេទិសនៃការអនុវត្តថវិកា រួមមាន៖

ក. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ខ. អាជ្ញាធរសវនកម្មជាតិ

គ. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ឃ. ក្រុមហ៊ុនសវនកម្មឯករាជ្យ

**៣. អធិការកិច្ច**

ក្នុងករណីមានវិវាទកើតឡើង ឬដើម្បីបង្ការ និងទប់ស្កាត់ភាពមិនប្រក្រតីនានា នៅតាមសាលារៀនសាធារណៈ អគ្គាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចចុះធ្វើអធិការកិច្ចជាប្រចាំ។

សម្គាល់៖ ក្នុងករណីការចុះធ្វើសវនកម្ម និងអធិការកិច្ចនៅតាមសាលារៀនសាធារណៈ ហើយរកឃើញកំហុសដោយចេតនា អ្នកពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តការដាក់ពិន័យ ឬ ផ្តន្ទាទោសទៅតាមបទបញ្ញត្តិនៃច្បាប់ដែលមានចែងជាធរមាន។

## ២.១៤ ការងារចុងការិយបរិច្ឆេទ

ដើម្បីធានាភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃឯកសារហិរញ្ញវត្ថុ នៅចុងការិយបរិច្ឆេទនីមួយៗ ហេរញ្ញិក និងប្រធាន គ.ម.ស. ត្រូវអនុវត្តដូចខាងក្រោម៖

**១. ការងារចុងខែ**

១.១ ពិនិត្យឡើងវិញឯកសារបញ្ជីគណនេយ្យ និងឯកសារគាំទ្រ

១.២ ពិនិត្យ និងបិទបញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារប្រចាំខែ

១.៣ ពិនិត្យ និងបិទបញ្ជីបេឡាប្រចាំខែ

១.៤ រៀបចំរបាយការណ៍តាមដានវឌ្ឍនភាពប្រចាំខែ

**២.ការងារចុងត្រីមាស**

២.១ រៀបចំរបាយការណ៍ទូទាត់ចំណាយថវិកាប្រចាំត្រីមាស

២.២ រៀបចំរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងសកម្មភាពប្រចាំត្រីមាស

២.៣ រៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស

**៣.ការងារចុងឆ្នាំ**

៣.១ បូកសរុបរបាយការណ៍ទូទាត់ចំណាយថវិកាប្រចាំឆ្នាំ

៣.២ បូកសរុបរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច និងសកម្មភាពប្រចាំឆ្នាំ

៣.៣ បូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ

៣.៤ ពិនិត្យ និងរៀបចំទុកដាក់ឯកសារហិរញ្ញវត្ថុ និងគណនេយ្យឱ្យបានត្រឹមត្រូវ សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម

## ២.១៥.ប្រព័ន្ធគ្រប់គ្រងឯកសារ

១. គោលការណ៍ សាលារៀនសាធារណៈត្រូវរក្សាឯកសារសម្រាប់ការគ្រប់គ្រង និងការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ ដោយត្រូវរក្សាទុកក្នុងក្រូណូឱ្យបានត្រឹមត្រូវ ។ ដើម្បីងាយស្រួលក្នុងការពិនិត្យ និង ថែទាំ គ.ម.ស. ត្រូវមានក្រូណូ ចំនួន ០៣ ប្រភេទ ដាច់ពីគ្នា រួមមាន៖

-ក្រូណូទី១ សម្រាប់ការងារប្រតិបត្តិការបច្ចេកទេស

-ក្រូណូទី២ សម្រាប់ការងារប្រតិបត្តិការហិរញ្ញវត្ថុ

-ក្រូណូទី៣ សម្រាប់របាយការណ៍ ។

២. ការរៀបចំឯកសារជាក្រុមសម្រាប់សាលារៀន

១- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន
២- ផែនការយុទ្ធសាស្ត្រថវិកា
៣- ផែនការថវិកាប្រចាំឆ្នាំ
៤- ផែនការប្រតិបត្តិប្រចាំឆ្នាំ

⇒ ក្រូណូទី១ ឯកសារប្រតិបត្តិការ បច្ចេកទេស

១- ប័ណ្ណចំណូលនិងឯកសារគាំទ្រ
២- ប័ណ្ណចំណាយនិងឯកសារគាំទ្រ
៣- បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារ
៤- បញ្ជីបេឡា
៥- របាយការណ៍ចំណាយថវិកាប្រចាំត្រីមាស និងឆ្នាំ

⇒ ក្រូណូទី២ ឯកសារ ប្រតិបត្តិការ ហិរញ្ញវត្ថុ

១- របាយការណ៍តាមដានវឌ្ឍភាពប្រចាំខែ
២- របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងឆ្នាំ
៣- របាយការណ៍ចុះពិនិត្យតាមដានពីអង្គភាពពាក់ព័ន្ធ
៤- របាយការណ៍អធិការកិច្ចពីអង្គភាពពាក់ព័ន្ធ
៥- របាយការណ៍សវនកម្មពីអង្គភាពពាក់ព័ន្ធ

⇒ ក្រូណូទី៣ ឯកសាររបាយការណ៍

# ជំពូកទី ៣
# សាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកតាមបែបគោលបំណងក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ ដោយដៅតែសំណាកណាដែលអ្នកស្រាវជ្រាវយល់ថា ភាគសំណាកនោះអាចផ្តល់នូវទិន្នន័យបានជាក់លាក់ច្បាស់លាស់ និងអាចឆ្លើយតបទៅនឹងប្រធានបទនេះបាន។ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីទីតាំងភូមិសាស្ត្រ និងភាគសំណាក ឧបករណ៍ស្រាវជ្រាវ ដំណើរការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១.ទីកន្លែងសិក្សាស្រាវជ្រាវ

ការសិក្សានេះ ជ្រើសរើសយកខេត្តត្បូងឃ្មុំជាទីតាំងសម្រាប់ធ្វើការប្រមូលទិន្នន័យ ។ ដូចដែលបានរៀបរាប់ក្នុងជំពូកទី១ខាងលើ ការស្រាវជ្រាវនេះមានវត្ថុបំណងសំខាន់ៗចំនួនពីរគឺ ៖

៣.១.១សិក្សាពីដំណើរការនៃការរៀបចំការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យ។

៣.១.២កំណត់ពីផែនការសកម្មភាពដើម្បីឆ្លើយជាដំណោះស្រាយនឹងបញ្ហាប្រឈម ដោយផ្អែកទៅលើកត្តាភេទ កម្រិតនៃការអប់រំ ប្រភេទសមាជិក កម្រិតវិជ្ជាជីវៈ និងបទពិសោធន៍ ។ ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើនេះ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ ព្រមទាំងបូកផ្សំជាមួយនឹងព័ត៌មានពីការអង្កេតផ្ទាល់របស់អ្នកស្រាវជ្រាវ ទៅលើស្ថានភាពជាក់ស្តែងរបស់វិទ្យាល័យនីមួយៗដែលបានជ្រើសរើសទាំងនោះ ។

## ៣.២.ភាគសំណាក

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែលមានការចូលរួមពីភាគីពាក់ព័ន្ធដូចជា នាយក នាយករង/នាយិការង ហេរញ្ញិក សហគមន៍ តំណាងគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស ។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមាននាយកសាលា ១០នាក់ នាយករង/នាយិការង ២០នាក់ ហេរញ្ញិក១០នាក់ សហគមន៍១៨នាក់ តំណាងគ្រូបង្រៀន ២០នាក់ ប្រធានក្រុមបច្ចេកទេស ១៥៨នាក់ ដែលបានជ្រើសរើសចេញពី វិទ្យាល័យចំនួន ១០ ក្នុងក្រុង/ស្រុកចំនួន៧ នៅក្នុងខេត្តត្បូងឃ្មុំតែប៉ុណ្ណោះ ។ សូមបញ្ជាក់ផងដែរ ខេត្តត្បូងឃ្មុំមានក្រុងចំនួន១និងស្រុកចំនួន៦ និងមានវិទ្យាល័យចំនួន២៤ ។ ក្នុងនេះផងដែរយើងបានជ្រើសរើសវិទ្យាល័យចំនួន១០ដែលស្មើ៤២% នៃវិទ្យាល័យដែលមានការអនុវត្តមូលនិធិដំណើរការសាលារៀន ។ មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវរើសយកវិទ្យាល័យទាំង១០ គឺដើម្បីយកមកធ្វើការប្រៀបធៀបគ្នាលើផ្នែកមួយចំនួនលើប្រសិទ្ធភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ។ រីឯសំណាកដែលត្រូវជ្រើសរើសមកបំពេញកម្រងសំណួរ និងសម្ភាស គឺយើងធ្វើការជ្រើសរើសតាមទំហំ និងស្ថានភាពសាលារៀនចំពោះ គ្រូ និងសិស្ស ។ ចំណែកនាយកសាលា (១នាក់ក្នុងមួយសាលារៀន) នាយករង/នាយការង(២នាក់ក្នុងមួយសាលារៀន) សហគមន៍ (១-២នាក់ក្នុងមួយសាលារៀន) ប្រធានក្រុម

បច្ចេកទេស (១៣-១៦នាក់ក្នុងមួយសាលា) តំណាងគ្រូបង្រៀន (២នាក់ក្នុងមួយសាលារៀន) ហេរញ្ញិក (១នាក់ក្នុងមួយសាលារៀន) យើងបានធ្វើការណាត់ជួបភាគសំណាកទាំងអស់ជាមុនទៅតាមពេលវេលាដែលបានកំណត់ ។

តារាងទី១៖ ចំនួនសំណាករងសម្ភាសន៍តាមសាលាទាំង១០

| ឈ្មោះវិទ្យាល័យ | ចំនួនអ្នកចូលរួមផ្តល់ព័ត៌មាន |
|---|---|
| វិទ្យាល័យក្រែក | ២២នាក់ |
| វិទ្យាល័យហ៊ុនសែនពញាក្រែក | ២៤នាក់ |
| វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ២៣នាក់ |
| វិទ្យាល័យសម្តេចម៉ែ | ២៤នាក់ |
| វិទ្យាល័យហ៊ុនសែន អូរាំងឪ | ២៤នាក់ |
| វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន មេមត់ | ២៤នាក់ |
| វិទ្យាល័យហ៊ុនសែន ចារថ្មី | ២៣នាក់ |
| វិទ្យាល័យហ៊ុន សែនតំបែរ | ២៤នាក់ |
| វិទ្យាល័យអម្ពវ័នជំនីក | ២៤នាក់ |
| វិទ្យាល័យក្រូចឆ្មារ | ២៤នាក់ |
| សរុប | ២៣៦នាក់ |

តារាងទី២បង្ហាញពីតួនាទី/មុខតំណែងអ្នករងសម្ភាសន៍

**Status**

| | | Frequency | Percent | Valid Percent | Cumulative Percent |
|---|---|---|---|---|---|
| Valid | Director | 10 | 4.2 | 4.2 | 4.2 |
| | Vice Director | 20 | 8.5 | 8.5 | 12.7 |
| | Teller/Accountant | 10 | 4.2 | 4.2 | 16.9 |
| | Community member | 18 | 7.6 | 7.6 | 24.6 |
| | Technical Teacher Leader | 158 | 66.9 | 66.9 | 91.5 |
| | Teacher Representative | 20 | 8.5 | 8.5 | 100.0 |
| | Total | 236 | 100.0 | 100.0 | |

តារាងទី៣បង្ហាញពីវប្បធម៌ទូទៅអ្នករងសម្ភាសន៍ ( គិតជាភាគរយ )

| កម្រិតវប្បធម៌ | បរិ.ជាន់ខ្ពស់ | បរិ | បរិ.រង | ទុតិយភូមិ | ក្រោមទុតិយភូមិ |
|---|---|---|---|---|---|
| | ៥.៩៤% | ៨១.៣៦% | ២.៥៤% | ២.៥៤% | ៧.៦២% |

តារាងទី៤បង្ហាញពីភាគរយភេទអ្នករងសម្ភាសន៍

| ភេទ | |
|---|---|
| ស្រី | ប្រុស |
| ១៦.៥៣% | ៨៣.៤៧% |

តារាងទី៥ បង្ហាញពីភាគរយជំនាញឯកទេស/វិជ្ជាជីវៈ /មុខរបរអ្នករងសម្ភាសន៍

| ឯកទេស/វិជ្ជាជីវៈ /មុខរបរអ្នករងសម្ភាសន៍ | | |
|---|---|---|
| គ្រូកម្រិតឧត្តម | គ្រូកម្រិតមូលដ្ឋាន | ប្រជាពលរដ្ឋ |
| ៧១.១៩% | ២១.១៩% | ៧.៦៣% |

ក្រាហ្វិកទី៦ បង្ហាញពីភាគរយបទពិសោធន៍ក្នុងវិស័យអប់រំ




## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរដែលជា លក្ខណៈកម្រិតចម្លើយ និងសំណួរទម្រង់បើកសម្រាប់នាយក នាយករង/នាយិការង តំណាងលោកគ្រូ អ្នកគ្រូ សហគមន៍ ហេរញ្ញិក និងប្រធានក្រុមបច្ចេកទេស ។ កម្រងសំណួរមានបីប្រភេទ ត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យរួមមាន ៖

កម្រងសំណួរសម្រាប់នាយក នាយករង/នាយិការងសាលា សម្រាប់លោកគ្រូ-អ្នកគ្រូ (ប្រធានក្រុមបច្ចេកទេស ហេរញ្ញិកនិងតំណាងគ្រូបង្រៀន) និងសម្រាប់សហគមន៍ ។ ក្នុងការសិក្សាស្រាវជ្រាវនេះ យើងប្រើប្រាស់កម្រងសំណួរចំនួន៣០ច្បាប់ សម្រាប់នាយក នាយករង/នាយិការង ១៨៨ច្បាប់ សម្រាប់ហេរញ្ញិក តំណាងគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស សហគមន៍ ១៨ច្បាប់ សរុបទាំងអស់មាន ២៣៦ច្បាប់ ។ ក្នុងការបង្កើតកម្រងសំណួរនេះយើងខ្ញុំបានរៀបចំតាក់តែង ខ្លឹមសារ កម្រងសំណួរ ស្របនឹងការអនុវត្តមូលនិធិដំណើរការសាលារៀនដោយផ្អែកលើគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈមានប្រសិទ្ធភាព ។

## ៣.៤.កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ

កម្រងសំណួរបែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទនិងកម្រងសំណួរ សម្រាប់សម្ភាស ៖

ក. កម្រងសំណួរទម្រង់បិទបែងចែកជាពីរផ្នែកគឺ៖

- ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៧សំណួរ ។ អ្នកស្រាវជ្រាវចង់ ដឹងអំពីភេទ កម្រិតវប្បធម៌ អំពីកម្រិតវិជ្ជាជីវ និងបទពិសោធន៍ការងារ ចំណេះដឹងភាសាបរទេស កុំព្យូទ័ររបស់អ្នកបំពេញកម្រងសំណួរ ។

- ផ្នែកទី២ ប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន នៅក្នុងផ្នែកនេះ អ្នកស្រាវជ្រាវចង់ស្វែងរកឱ្យឃើញពីចំណុចមួយចំនួននៃការអនុវត្តការមូលនិធិដំណើរការសាលារៀនដែលបានអនុវត្តកន្លងមកថាតើមានប្រសិទ្ធភាពដល់កម្រិតណាទាក់ទងនឹង៖

(១) ការរៀបចំផែនការថវិកា

(២) ការអនុវត្តចំណូល ចំណាយ

(៣) ការត្រួតពិនិត្យតាមដាន

ខ. កម្រងសំណួរសម្រាប់សម្ភាស គឺចង់វាស់ស្ទង់មតិរបស់គណៈកម្មការមូលនិធិដំណើការសាលារៀន បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ ។

## ៣.៥ ដំណើរការប្រមូលទិន្នន័យ

មុនពេលផ្តល់កម្រងសំណួរនេះដល់អ្នកចូលរួមផ្តល់ព័ត៌មាន ជាដំបូងអ្នកស្រាវជ្រាវបានធ្វើលិខិតស្នើសុំចុះប្រមូលទិន្នន័យពីវិទ្យាស្ថានជាតិអប់រំ បន្ទាប់មកយកទៅប្រគល់ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចមក អ្នកស្រាវជ្រាវ ក៏បានកយកលិខិតស្នើសុំនោះទៅប្រគល់ជូនលោកនាយកសាលារៀន និងដើម្បីសុំការអនុញ្ញាតក្នុងការចុះប្រមូលទិន្នន័យព្រមទាំងសម្ភាសលើសំណាកដែលមាននាយក នាយករង/នាយិការង តំណាងគ្រូបង្រៀន ប្រធានក្រុមបច្ចេកទេស សហគមន៍ ហេរញ្ញិក ។ បន្ទាប់មកទៀតបានផ្តល់កម្រងសំណួរដល់ អ្នកទាំងអស់នេះដើម្បីបំពេញ និងធ្វើការសម្ភាស ។

## ៣.៦ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើ ប្រាស់កម្មវិធី SPSS ដើម្បីបញ្ចូល និងវិភាគទិន្នន័យ និងប្រើកម្មវិធី Ms. Excel ដើម្បីបង្ហាញតារាង និងតារាងក្រាហ្វិកក្នុងការវិភាគបែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតចម្លើយនៃ សកម្មភាពនានាដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការអនុវត្តការមូលនិធិដំណើរការតាមសាលារៀនដោយគិតជាចំនួនធម្យម និងភាគរយ ។ ចំណែកសំណួរបើកវិញជាសំណួរបែបគុណវិស័យ គឺវិភាគដោយប្រើប្រាស់កម្មវិធី SPSS និង Ms. Word ។ ដូច្នេះនៅក្នុងការវិភាគចម្លើយ ចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគគឺអាស្រ័យទៅលើប្រភេទនៃសំណួរថាតើវាជាប្រភេទសំណួរបើកឬសំណួរបិទ ។

## ៣.៧ ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបានផ្ដល់ដំណឹងបន្តទៅ ដល់មូលដ្ឋាន ក្នុងការសុំជួបសម្ភាសជាមួយ នាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន ។ នៅគ្រប់ការជួបសម្ភាសជាមួយ នាយក គ្រូ សិស្ស សហគមន៍ និងគណៈកម្មការគ្រប់គ្រងសាលារៀន យើងតែងតែជម្រាបពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវ ដែលរក្សានូវការសម្ងាត់ នូវរាល់ចម្លើយរបស់នាយក គ្រូ ដែលមិនបានបង្ហាញពីឈ្មោះរបស់អ្នកចូលរួមឆ្លើយពិតប្រាកដនោះទេ ដើម្បីទាមទារឱ្យបានចម្លើយដែលពិតប្រាកដ ។

# ជំពូកទី ៤
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤

# លទ្ធផលការស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវ នឹងបង្ហាញនូវលទ្ធផលដែលប្រមូលបានទៅតាម ខ្លឹមសារនៃកម្រងសំណួរម្តងមួយៗ តាមរយៈតារាង ហើយនិងធ្វើការបកស្រាយ លើខ្លឹមសារនៃការអនុវត្តមូលនិធិដំណើរការសាលារៀន ។

## ៤.១ លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.១.១ ការរៀបចំផែនការថវិកាមូលនិធិដំណើរការសាលារៀន

ក្រោយពេលបូកសរុបទិន្នន័យវិទ្យាល័យ ដែលប្រមូលបានពីការបំពេញកម្រងសំណួរ និងឆ្លើយសំណួរសម្ភាសន៍រួចមក អ្នកសិក្សាស្រាវជ្រាវរកឃើញថា អ្នកចូលរួមឆ្លើយក្នុងការ ផ្តល់ព័ត៌មាន សរុបមានចំនួន ២៣៦នាក់ ស្រី ៣៩នាក់ ដែលក្នុងនោះ នាយកសាលា ១០នាក់ ស្រី០នាក់ នាយករង/នាយិការង ២០នាក់ ស្រី២នាក់ សហគមន៍ ១៨នាក់ ស្រី០នាក់ ហេរញ្ញិក ១០នាក់ ស្រី ១នាក់ គ្រូបង្រៀន ១៧៨ នាក់ ស្រី ៣៦នាក់ (តារាងទី១) ។

ស្ថិតិដែលប្រើរីភាគរួមមាន មធ្យមភាគ(Mean) គម្លាតស្តង់ដា(Standard deviation) ដើម្បីបង្ហាញឲ្យឃើញនូវកម្រិតនៃការចូលរួមធ្វើផែនការថវិកា។ យោងតាម ការបែងចែកកម្រិតដែលចងក្រងដោយ Oxford និងBurry-Stock (1995) កម្រិតមធ្យមត្រូវបានគេបែងចែកជា បីក្រុម គឺកម្រិតខ្ពស់ (M=3.50 ឡើង) កម្រិតមធ្យម (M=2.50 – 3.49) និងកម្រិតទាប (M=2.49 ចុះ)។

*Q2.តើគណៈកម្មការមូលនិធិដំណើរការសាលារៀនបានចូលរួមរៀបចំផែនការថវិកាផែនការអភិវឌ្ឍន៍សាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនកម្រិតណា?*

**តារាងទី៧៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការចូលរួមរៀបចំផែនការថវិកា**

| ល.រ | ឈ្មោះវិទ្យាល័យ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.១៤ | ០.៧១ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៩៦ | ០.២០ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៨៧ | ០.៦២ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៦៣ | ០.៦៤ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូររាំងឪ | ១.៥៨ | ០.៥០ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៤៦ | ០.៥១ | ទាបបំផុត |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៨៨ | ០.៨៧ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៨៣ | ០.៧០ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក | ១.៥៤ | ០.៥៩ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៧៩ | ០.៨៣ | ទាប |

ការរៀបចំផែនការថវិកាមានលក្ខណៈជាយុទ្ធសាស្ត្រពីព្រោះគ្រប់ភាគីពាក់ព័ន្ធនៃគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនបានឆ្លើយថាពួកគាត់បានចូលរួមប្រជុំពិគ្រោះយោបល់កំណត់ពីតម្រូវការរបស់សាលារៀនក្នុងរវាងខែមករា មីនា ឧសភា និងកក្កដាអំពីតម្រូវការជាក់ស្តែងរបស់សាលា សហគមន៍ មាតាបិតាសិស្ស ហើយបានប្រជុំរៀបចំជាសកម្មភាពសម្រាប់អនុវត្តនាឆ្នាំសិក្សាថ្មីដោយមានការឯកភាពគ្នា ហើយស្របតាមធនធានហិរញ្ញវត្ថុដែលសាលាមានតាមការកំណត់របស់ថ្នាក់មន្ទីរ ថវិកាដៃគូអភិវឌ្ឍន៍ ។ ប្រសិនបើមានការខ្វះខាតគណៈកម្មការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ធ្វើការកៀរគរថវិកាពីអាណាព្យាបាលពេលប្រជុំប្រចាំខែជាមួយមាតាបិតាសិស្សដោយមានការគាំទ្រពីអាជ្ញាធរដែនដីហើយថវិកាត្រូវបានចុះចូលក្នុងបញ្ជីបេឡានិងប្រកាសជាសាធារណៈរៀងរាល់ខែនៅក្តារខៀនព័ត៌មានក្នុងសាលានៅថ្នះមេភូមិ ។ សាលាដែលអនុវត្តបានល្អជាងគេវិទ្យាល័យក្រែក(M=២.១៤) និង(Standard deviation=0.៧១) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនមេមត់(M=១.៤៦) និង(Standard deviation=0.៥១) ។

*Q3.តើគណៈកម្មការមូលនិធិដំណើរការសាលារៀនបានចូលរួមផ្តល់ធាតុចូលថ្មីៗក្នុងការរៀបចំផែនការថវិកាផែនការអភិវឌ្ឍន៍សាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនកម្រិតណា?*

**តារាងទី៨៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការចូលរួមផ្តល់ធាតុចូលថ្មីៗ**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.២៧ | 0.៦៣ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៥៤ | 0.៥១ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ២.១៧ | 0.៧២ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៧0 | 0.៦៥ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៥១ | 0.៥0 | ទាបបំផុត |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៦0 | 0.៥៥ | ទាប |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៨0 | 0.៨៥ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៦៣ | 0.៧0 | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពិលនៃជំនីក | ១.៨២ | 0.៧៨ | ទាប |
| ១0 | វិទ្យាល័យក្រូចឆ្មារ | ១.៩២ | 0.៧១ | ទាប |

មានន័យថារាល់ការប្រជុំគណៈកម្មការបានចូលរួមធ្វើផែនការតែការរកធាតុចូលថ្មីៗ វិទ្យាល័យក្រែកធ្វើបាន (M=២.២៧) និង(Standard deviation=0.៦៣) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនអូរាំងឪ(M=១.៥១) និង(Standard deviation=0.៥0) ដោយសារតែកម្រិតចំណេះដឹង និងបទពិសោធន៍ ទាក់ទងនឹងវិស័យអប់រំនៅមានកម្រិត ។

*Q4.កម្រិតនៃការចូលរួមរបស់គណៈកម្មការមូលនិធិសាលារៀនប្រជុំប្រឹក្សាយោបល់ស្វែងរកតម្រូវការអាទិភាពដើម្បីអភិវឌ្ឍន៍សាលា*

**តារាងទី៩៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការចូលរួមរបស់គណៈកម្មការប្រជុំប្រឹក្សាយោបល់កំណត់តម្រូវការអាទិភាព (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.០០ | 0.៦២ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៦០ | 0.៥០ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ២.៥០ | 0.៧៤ | មធ្យម |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៥០ | 0.៦៦ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៥៩ | 0.៥៨ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៦៨ | 0.៨២ | ទាប |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៤៣ | 0.៥១ | ទាបបំផុត |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៩០ | 0.៨០ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉នជំនីក | ១.៦៣ | 0.៨២ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៩២ | 0.៦៥ | ទាប |

មានន័យថារាល់ការប្រជុំគណៈកម្មការបានចូលរួមកំណត់ផែនការអាទិភាពវិទ្យាល័យ សម្តេចតេជោហ៊ុនសែន សួងធ្វើបានកម្រិតមធ្យមគឺ (M=២.៥០) និង(Standard deviation=0.៧៤) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនចារថ្មី(M=១.៤៣) និង(Standard deviation= 0.៥១) ដោយសារតែកម្រិត នៃការយល់ដឹងពីគោលនយោបាយអប់រំ បរិបទសង្គម នៅមានកម្រិត។

### ៤.១.២ ការអនុវត្តចំណូល ចំណាយ

*Q5.តើការធ្វើរបាយការណ៍ចំណូល- ចំណាយ របាយការណ៍/ឯកសារទូទាត់និងរបាយការណ៍សមិទ្ធកម្មមូលនិធិដំណើរការសាលារៀនទាន់កាលកំណត់របស់ថ្នាក់ស្រុក មន្ទីរឬទេ?*

**តារាងទី១០៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការធ្វើរបាយការណ៍ (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.០០ | 0.២១ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៤០ | 0.៥០ | ទាបបំផុត |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ២.0២ | 0.៧៤ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៧០ | 0.៧០ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៦៨ | 0.៦៤ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៥០ | 0.៥១ | ទាប |

| | | | | |
|---|---|---|---|---|
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៦១ | ០.៦៦ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៦៣ | ០.៥៨ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីក | ១.៨០ | ០.៧៨ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៩០ | ០.៧៤ | ទាប |

មាននំយថាគណៈកម្មការមូលនិធិដំណើរការសាលារៀនបានចូលរួមធ្វើរបាយការណ៍ទូទាត់ គឺវិទ្យាល័យ សម្តេចតេជោ ហ៊ុនសែន សួងធ្វើបាន (M=២.០២) និង ( Standard deviation = ០.៧៤) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនពញាក្រែក (M = ១.៤០ ) និង( Standard deviation = ០.៥០ ) ដោយសារតែកម្រិត នៃការយល់ដឹងពីប្រភេទឯកសារទូទាត់នៅមានកម្រិត។

*Q10 តើកិច្ចបញ្ជីការគណនេយ្យមូលនិធីដំណើរការសាលារៀនអនុវត្តបានកម្រិតណា?*

**តារាងទី១១៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃកិច្ចបញ្ជីការគណនេយ្យ (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.៤១ | ០.៥០ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៤០ | ០.៤៩ | ទាបបំផុត |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៨៧ | ០.៧៦ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៥៨ | ០.៦៥ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៤៦ | ០.៥៩ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៤២ | ០.៥០ | ទាប |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៥២ | ០.៦៧ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៨០ | ០.៧៨ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីក | ១.៧១ | ០.៧៥ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៦៣ | ០.៥០ | ទាប |

វិទ្យាល័យក្រែកបានអនុវត្តកិច្ចបញ្ជីការគណនេយ្យ (M=២.៤១) និង ( Standard deviation = ០.៥០ ) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនពញាក្រែក (M = ១.៤០ ) និង( Standard deviation = ០.៤៩ ) ដោយសារតែកម្រិតនៃការកិច្ចបញ្ជីការគណនេយ្យនៅមានកម្រិត។ ការកត់ត្រាចំណូល - ចំណាយ មូលនិធិដំណើរការសាលារៀនគឺធ្វើឡើងតាមនីតិវិធីគណគណនេយ្យ ។ នៅពេលមានសាច់ប្រាក់ចូលគឺត្រូវកត់ចូលក្នុងបញ្ជីបេឡាសាលារៀន/បញ្ជីតាមដានសាច់ប្រាក់ក្នុងធនាគារតាម គណនី ជំពូក មាតិកាចំណូល-ចំណាយ តាមលេខយោងប័ណ្ណបង់ប្រាក់/ប្រកាសឥណទានរបស់ធនាគារ ហើយប្រកាស និងបិទផ្សាយឱ្យគណៈកម្មការទាំងអស់បានដឹង ។ បន្ទាប់មកប្រជុំធ្វើការបែងចែកចំណូលទៅតាមសកម្មភាព ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍សាលារៀន ផែនការថវិកាប្រចាំឆ្នាំរបស់សាលា ។ពេលដកសាច់ប្រាក់ពីធនាគារត្រូវមានសំណើសុំដកប្រាក់ហើយកត់ត្រាចូលបញ្ជីតាមដានសាច់ប្រាក់ក្នុង

ធនាគារ លេខយោងប័ណ្ណបើក/ដកសាច់ប្រាក់ឬមូលប្បទានប័ត្រឬប្រកាសឥណពន្ធ(ធនាគារ) ។ នៅក្នុងបញ្ជីបេឡាសាលារៀនត្រូវកត់ត្រាក្នុង ប័ណ្ណចំណូល អ្វីដែលខ្វះខាតគឺការចុះចូលមានភាពយឺតយ៉ាវ មិនទៀងទាត់រាល់ថ្ងៃ។

*Q12 តើលោក លោកស្រីទូទាត់ចំណាយមូលនិធិដំណើរការសាលារៀនបានកម្រិតណា?*

**តារាងទី១២៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃទូទាត់ចំណាយ (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.១០ | ០.៤៣ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៧១ | ០.៦២ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៧៨ | ០.៦៧ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៧១ | ០.៥៥ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឳ | ១.៨០ | ០.៤២ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៦៣ | ០.៥០ | ទាប |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៥២ | ០.៥១ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៧៥ | ០.៤៤ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ៉ែនជំនីក | ១.៤២ | ០.៤៩ | ទាបបំផុត |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៥៨ | ០.៥០ | ទាប |

វិទ្យាល័យក្រែកបានអនុវត្តការទូទាត់ចំណាយ (M=២.១០) និង (Standard deviation = ០.៤៣ ) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យអម្ពវ៉ែនជំនីក (M = ១.៤២ )និង ( Standard deviation = ០.៤៩ ) ។

*Q13 តើឯកសារគាំទ្រសម្រាប់ការទូទាត់ចំណាយមូលនិធិដំណើរការសាលារៀនបានទាន់ពេលវេលាកម្រិតណា?*

**តារាងទី១៣៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការផ្តល់ឯកសារគាំទ្រសម្រាប់ការទូទាត់ចំណាយ (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ១.៩១ | ០.៧៥ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៦៧ | ០.៥៧ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៦៥ | ០.៤៩ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៥៤ | ០.៥៩ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឳ | ១.៧១ | ០.៤៦ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៨៣ | ០.៤៨ | ទាប |

| | | | | |
|---|---|---|---|---|
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៥២ | 0.៥១ | ទាបបំផុត |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៧0 | 0.៤៦ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្លាំងនជំនីក | ១.៥៨ | 0.៥0 | ទាប |
| ១0 | វិទ្យាល័យក្រូចឆ្មារ | ១.៦0 | 0.៥៨ | ទាប |

វិទ្យាល័យក្រែកបានផ្តល់ឯកសារសម្រាប់ទូទាត់ចំណាយ (M=១.៩១) និង ( Standard deviation = 0.៧៥ ) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនចារថ្មី(M = ១.៥២ ) និង( Standard deviation = 0.៥១ ) ។ រាល់ការចំណាយនៅពេលទទួលបានសំណើសុំចំណាយសាច់ប្រាក់ត្រូវដកពីបេឡាសាលារៀនតាមចំណាយលើសកម្មភាពជាក់ស្តែងដោយភ្ជាប់មកនូវសំណើសុំចំណាយ ដែលមានការឯកភាពពីប្រធានគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ។ នៅពេលអនុវត្តសកម្មភាពចប់រួចរាល់ ត្រូវមានទូទាត់ទៅតាមគោលការណ៍គណនេយ្យដោយភ្ជាប់មកជាមួយនូវឯកសារផ្សេងៗដូចជា សំណើចំណាយ វិក្កយបត្រ ប័ណ្ណចំណាយ បញ្ជីវត្តមាន របាយការណ៍លទ្ធផល របៀបវារៈប្រជុំ តារាងបើកប្រាក់ឧបត្ថម្ភ លិខិតឧទ្ទេសនាម កំណត់ហេតុ ។

*Q18 តើការផែនការសកម្មភាពចំណូល-ចំណាយ ការបែងចែកថវិកាមូលនិធិដំណើរការសាលារៀនមានតម្លាភាពកម្រិតណា?*

**តារាងទី១៤៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃបែងចែកថវិកា (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ១.៨២ | 0.៤0 | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៥៤ | 0.៥១ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៥៧ | 0.៥១ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៧១ | 0.៤៦ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៧២ | 0.៤៦ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៦៧ | 0.៤៨ | ទាប |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៥២ | 0.៥១ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៥៨ | 0.៥0 | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្លាំងនជំនីក | ១.៤៦ | 0.៥១ | ទាបបំផុត |
| ១0 | វិទ្យាល័យក្រូចឆ្មារ | ១.៦៣ | 0.៦៥ | ទាប |

វិទ្យាល័យក្រែកបានអនុវត្តការបែងចែកថវិការបស់មូលនិធិដំណើរការសាលារៀន (M=១.៨២) និង ( Standard deviation = 0.៤0 ) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័ប៊ុនរ៉ានីហ៊ុនសែនអម្លាំងនជំនីក (M = ១.៤៦ ) និង( Standard deviation = 0.៥១ ) ។

### ៤.១.៣ ការពិនិត្យតាមដាននិងវាយតម្លៃ

*Q6.តើលោក-អ្នកអនុវត្តផែនការចុះពិនិត្យតាមដានលើឯកសារនិងរបាយការណ៍មូលនិធិដំណើរការសាលារៀនបានកម្រិតណា?*

**តារាងទី១៥៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃអនុវត្តផែនការចុះពិនិត្យតាមដានលើឯកសារនិងរបាយការណ៍មូលនិធិដំណើរការសាលារៀន (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.១៤ | ០.៨៣ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៦៣ | ០.៥០ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៩១ | ០.៧៣ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៦៣ | ០.៧១ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៦៧ | ០.៧៦ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៤៦ | ០.៦៦ | ទាបបំផុត |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៥៧ | ០.៧៣ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៧១ | ០.៧៥ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក | ១.៧៩ | ០.៨៣ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៧៩ | ០.៦៥ | ទាប |

វិទ្យាល័យក្រែកបានអនុវត្តផែនការចុះពិនិត្យតាមដានឯកសារនិងរបាយការណ៍មូលនិធិដំណើរការសាលារៀន (M=២.១៤) និង (Standard deviation =០.៨៣ ) ហើយសាលាដែលអនុវត្តកម្រិតទាបជាងគេគឺវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់(M = ១.៤៦ )និង( Standard deviation=០.៦៦ ) ។

*Q7.តើលោក-អ្នកអនុវត្តការប្រជុំឆ្លុះបញ្ចាំងពីកំហុសនិងវឌ្ឍនភាពបន្ទាប់ពីចុះពិនិត្យតាមដានលើឯកសារនិងរបាយការណ៍មូលនិធិដំណើរការសាលារៀនបានកម្រិតណា?*

**តារាងទី១៦៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃការប្រជុំឆ្លុះបញ្ចាំងកំហុសនិងវឌ្ឍនភាពបន្ទាប់ពីចុះពិនិត្យតាមដាន (N= 236)**

| ល.រ | សំណួរ | កម្រិតការអនុវត្ត | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ១.៨៦ | ០.៧១ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៤២ | ០.៥០ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៧៨ | ០.៧៤ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៤៦ | ០.៥៩ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៥៤ | ០.៥១ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៤២ | ០.៦៥ | ទាបបំផុត |

| | | | | |
|---|---|---|---|---|
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៧៤ | ០.៧៥ | ទាប |
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៧៥ | ០.៨៥ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក | ១.៨៨ | ០.៨៥ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៧១ | ០.៦២ | ទាប |

កម្រិតប្រជុំឆ្លុះបញ្ចាំងពីកំហុសនិងវឌ្ឍនភាពបន្ទាប់ពីចុះពិនិត្យតាមដានលើឯកសារនិងរបាយការណ៍មូលនិធិដំណើរការសាលារៀនគឺ វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីកអនុវត្តបាន (M=១.៨៨) និង ( Standard deviation = ០.៨៥ ) ហើយសាលាដែលអនុវត្តមានកម្រិតទាបជាងគេគឺវិទ្យាល័ប៊ុនរ៉ានីហ៊ុនសែនមេមត់ (M = ១.៤២ ) និង( Standard deviation = ០.៦៥ ) ។

ការពិនិត្យតាមដាន និងវាយតម្លៃមូលនិធិដំណើរការសាលារៀនគឺធ្វើឡើងតាមនីតិវិធីគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធីដំណើរការសាលារៀនរបស់នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៣ ដោយត្រួតពិនិត្យលើ៖

១.របាយការណ៍ចំណាយថវិកា(តារាងលេខ២.១កនិង ២.១ខ)

២.របាយការណ៍ទូទាត់ តារាងលេខ៣.១

៣.របាយការណ៍សមិទ្ធកម្ម

ការពិនិត្យតាមដានគឺដើម្បីធានាការអនុវត្តការងារ(ការចំណាយ )បានឆ្លើយតបទៅនឹងផែនការសកម្មភាពដែលបានអនុវត្តរួចហើយ ដោយអនុលោមតាមគោលការណ៍ចំណាយនិងថវិកាដែលបានឯកភាពឬទេ? ហើយលទ្ធផលអាចទទួលយកបានឬទេ ? មានផលប៉ះពាល់អ្វីខ្លះ ? ហើយមានសកម្មភាពអ្វីខ្លះត្រូវកែសម្រួល ? ។ ដូចនេះដើម្បីឱ្យការការពិនិត្យតាមដាន និងវាយតម្លៃទទួលបានលទ្ធផលល្អ គណៈកម្មការបានប្រជុំរៀបចំជាផែនការ ( ពេលវេលា សមាសភាព ចំណុចដែលត្រូវពិនិត្យ ) ។ នៅពេលពិនិត្យទៅមានកំហុសឆ្គង ធ្វើការប្រជុំកែតម្រូវ រកដំណោះស្រាយ ហើយរៀបចំផែនការសកម្មភាពជាថ្មី ។

*Q21.ការអនុវត្តមូលនិធិដំណើរការសាលារៀនជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ? កម្រិតណា?*

**តារាងទី១៧៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ កម្រិតនៃបញ្ហាប្រឈម (N= 236)**

| ល.រ | សំណួរ | កម្រិតបញ្ហា | | អត្ថន័យ |
|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | |
| ១ | វិទ្យាល័យក្រែក | ២.០៥ | ០.៤៩ | ទាប |
| ២ | វិទ្យាល័យហ៊ុនសែន ពញាក្រែក | ១.៥០ | ០.៥១ | ទាប |
| ៣ | វិទ្យាល័យសម្តេចតេជោហ៊ុនសែន សួង | ១.៥២ | ០.៥១ | ទាប |
| ៤ | វិទ្យាល័យសម្តេចម៉ែ | ១.៥៤ | ០.៥០ | ទាប |
| ៥ | វិទ្យាល័យហ៊ុនសែន អូរាំងឪ | ១.៨៣ | ០.៣៨ | ទាប |
| ៦ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ | ១.៦៧ | ០.៤៨ | ទាប |
| ៧ | វិទ្យាល័យហ៊ុនសែនចារថ្មី | ១.៣៩ | ០.៤៩ | ទាបបំផុត |

| | | | | |
|---|---|---|---|---|
| ៨ | វិទ្យាល័យហ៊ុនសែនតំបែរ | ១.៧៥ | ០.៤៤ | ទាប |
| ៩ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក | ១.៦៧ | ០.៤៨ | ទាប |
| ១០ | វិទ្យាល័យក្រូចឆ្មារ | ១.៧១ | ០.៦៩ | ទាប |

ការអនុវត្តមូលនិធិដំណើរការសាលារៀនមានបញ្ហាទាក់ទងនឹងការបំពេញឯកសារសម្រាប់ទូទាត់ការគ្រោងចំណាយលើសផែនការថវិកា មិនអាចបែងចែកថាសកម្មភាពណានៅក្នុងSOB ឬSOF ផែនការសកម្មភាពភាគច្រើនមិនឆ្លើយតបគោលបំណងនៃមូលនិធិដំណើរការសាលារៀន សកម្មភាពអាទិភាពមិនសូវឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សហគមន៍ មាតាបិតាសិស្ស លទ្ធផលសិក្សារបស់សិស្ស ។ តាមលទ្ធផលគឺ វិទ្យាល័យក្រែកមានកម្រិត (M=២.០៥) និង ( Standard deviation = ០.៤៩ ) ហើយសាលាដែលមានបញ្ហាកម្រិតទាបជាងគេគឺវិទ្យាល័យហ៊ុនសែនចារថ្មី(M = ១.៣៩ ) និង( Standard deviation = ០.៤៩ ) ។

## ៤.២ សារសំខាន់នៃមូលនិធិដំណើរការសាលារៀន

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ មូលនិធិដំណើរការសាលារៀនមានសារសំខាន់ ព្រោះវាជាប្រទីបដែលបង្ហាញផ្លូវអនុវត្តដើម្បីសម្រេចនូវផែនការសកម្មភាពដែលបានកំណត់ សូចនាករ គោលដៅច្បាស់លាស់ ។ រាល់បញ្ហាត្រូវបានដោះស្រាយដោយមានការចូលរួមពីសហគមន៍និងអ្នកពាក់ព័ន្ធនានា។ មិនតែប៉ុណ្ណោះបានបង្ហាញពីការអភិវឌ្ឍលើផ្នែកបរិស្ថាន គុណភាពសិក្សា គុណភាពបង្រៀន ការគ្រប់គ្រងថវិកាមានតម្លាភាព ។

## ៤.៣បញ្ហាប្រឈម ដំណោះស្រាយនៃការអនុវត្តមូលនិធិដំណើរការសាលារៀន

ការអនុវត្តមូលនិធិដំណើរការសាលារៀនមានបញ្ហាទាក់ទងនឹងការបំពេញឯកសារសម្រាប់ទូទាត់ការគ្រោងចំណាយលើសផែនការថវិកា មិនអាចបែងចែកថាសកម្មភាពណានៅក្នុងSOB ឬSOF

ចំណេះដឹងផ្នែកគណនេយ្យរបស់គណៈកម្មការនៅមានកម្រិត ការចំណាយភាគច្រើនលើតែផ្នែករដ្ឋបាលនិងបរិស្ថាន ការប្រជុំគណៈកម្មការពេលខ្លះពិបាកចាត់ចែង បញ្ហាខ្លះមិនអាចគ្រប់គ្រងបាន ការដោះស្រាយបញ្ហានៅមានកម្រិត ។ ទោះជាយ៉ាងណានៅពេលមានបញ្ហាគ្រប់សមាសភាពនៃគណៈកម្មការបានរៀបចំការប្រជុំដើម្បីរកពីមូលហេតុនៃបញ្ហា បន្ទាប់មករកវិធីដោះស្រាយទាំងនោះ បើមិនអាចដោះស្រាយបានបានស្នើសុំជំនួយទៅការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ឬមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ។

ដើម្បីធ្វើឱ្យសាលារៀនរីកចម្រើនគណៈគ្រប់គ្រងសាលា គណៈកម្មការមូលនិធិដំណើរការសាលារៀនបានបន្តសហការនិងគៀគរធនធានពីសហគមន៍ មាតាបិតាសិស្ស ដៃគូអភិវឌ្ឍ សិក្សាពីតម្រូវការជាក់ស្តែងហើយរៀបចំសកម្មភាពជាក់លាក់ដែលស្របតាមគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បរិបទទីផ្សារការងារក្នុងតំបន់និងពិភពលោក ។ ជាពិសេសបន្តបណ្តុះបណ្តាលគុណភាពសិស្ស ដើម្បីបង្កើនភាពជឿជាក់របស់មាតាបិតាសិស្សលើគុណភាពសិក្សា ជំនាញ សីលធម៌ ។

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ នឹងសង្កេតនៅតាមសាលារៀនគោលដៅទាំង១០ក្នុងខេត្តត្បូងឃ្មុំ លើប្រធានបទ « ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ » អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានជារួមបានថា ការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំនៅមានកម្រិតនៅឡើយទៅលើការរៀបចំផែនការថវិកាសាលារៀន ការផ្ដល់ធាតុចូលថ្មីៗ ការកំណត់តម្រូវការអាទិភាព ការអនុវត្តចំណូល ចំណាយ កិច្ចបញ្ជីការគណនេយ្យ ការទូទាត់ចំណាយ ផែនការសកម្មភាពចំណូល ចំណាយ ការបែងចែកថវិកា ការអនុវត្តផែនការចុះពិនិត្យតាមដានឯកសារនិងរបាយការណ៍ទូទាត់ ។

## ៥.២ សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវនេះបង្ហាញមូលនិធិដំណើរការសាលារៀនពិតជាមាន សារៈសំខាន់ណាស់សម្រាប់លើកកម្ពស់គុណភាពអប់រំឱ្យកាន់តែមានភាពប្រសើរឡើង ។ ជាងនេះទៅទៀតប្រសិនបើអង្គភាពសាធារណៈក្លាយជាអង្គភាពថវិកាពេញលេញ កាន់តែធ្វើឱ្យអង្គភាពមានការរីកចម្រើនខ្លាំង ការគ្រប់គ្រងថវិកាមានតម្លាភាពដូចជាស្ថាប័នឯកជន។ ស្របជាមួយគ្នានេះដែរការសិក្សាស្រាវជ្រាវលើប្រធានបទ “ ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ ”បានបង្ហាញថាស្ថានភាពនៃការអនុវត្តនៅតាមសាលារៀនគោលដៅទាំង១០នោះមិនទាន់បំពេញតាមគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ហើយនឹង គោលដៅអប់រំជាតិនៅឡើយទេ ។ ដូចនេះ ជាអ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួន ដែលពាក់ព័ន្ធនឹងស្ថានភាពការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យ ។ សំណូមពរទាំងនោះមានដូចជា ៖

-ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាក់ព័ន្ធគួររៀបចំបើកវគ្គបណ្ដុះបណ្ដាលជំនាញគ្រប់គ្រងមូលនិធិដំណើរការសាលារៀនដល់គណៈកម្មការមូលនិធិដំណើរការសាលារៀន នៅតាមវិទ្យាល័យឱ្យបានគ្រប់សាលា ពិសេសធ្វើឱ្យនាយក សហគមន៍យល់កាន់តែច្បាស់ពីសកម្មភាពដែលឆ្លើយតប ទៅនឹងអត្ថន័យ និងអត្ថប្រយោជន៍នៃខ្លឹមសារគោលនយោបាយអប់រំជាតិ ។

-ថ្នាក់ក្រសួងអប់រំ ថ្នាក់មន្ទីរអប់រំ ថ្នាក់ការិយាល័យអប់រំ ត្រូវចុះពិនិត្យតាមដានផ្ទាល់លើការអនុវត្តSOF នៅតាមសាលារៀន មួយត្រីមាសម្តង និងទៀតទាត់ សូមជៀសវាងរង់ចាំតែរបាយការណ៍ពីសាលារៀន ។

-នាយក គ្រូបង្រៀន ត្រូវមានទំនាក់ទំនងល្អជាមួយអាណាព្យាបាល មាតាបិតាសិស្សក្នុងការគៀងគរសិស្សអោយចូលរៀន និងមករៀនអោយបានទៀងទាត់ និងត្រូវស្វែងរកមូលហេតុឱ្យបានច្បាស់លាស់សម្រាប់ការអវត្តមានរបស់សិស្ស និងការបោះបង់របស់សិស្ស ។

-នាយកសាលាត្រូវមានទំនាក់ទំនងល្អជាមួយសហគមន៍ និងមាតាបិតាសិស្សក្នុងការតាមដានជំរុញលើកទឹកចិត្តសិស្សអោយមានការខិតខំសិក្សាបន្ថែមទាំងនៅសាលា និងនៅផ្ទះ ។

-ដៃគូអភិវឌ្ឍន៍ សហគមន៍គួរបន្តសហការនិងផ្តល់ជាធនធានបច្ចេកទេស ផ្តល់ការគាំទ្រដល់សាលារៀន ។

-មាតាបិតាសិស្សគួរបន្តសហការជាមួយសាលា ផ្តល់ការគាំទ្រដល់សាលារៀន ជាពិសេសចូលរួមលើកទឹកចិត្តកូនៗក្នុងការសិក្សា។

-អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ គួរតែពង្រីងវិសាលភាពនៃការសិក្សាស្រាវជ្រាវបន្ថែមទៀត ជាពិសេស ភាគសំណាកឱ្យបានធំជាងនេះ ឱ្យបានគ្រប់សាលារៀន ទូទាំងខេត្ត ឬទូទាំងប្រទេសជាដើម ។

# ឯកសារយោង

- ឯ.ឧបណ្ឌិត ហង់ជួន ណារុន, ២០១៤
- ប្រកាស អន្តរក្រសួងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ៣៦៦សហវ.ប្រក មាន៦ជំពូក ១៩ ប្រការ ចុះថ្ងៃទី០៦/០៥/២០១៥
- លិខិតលេខ ៣៤៣៦ អយក.ហវ ចុះថ្ងៃទី២៥/០៦/២០១៨
- លិខិតលេខ១០០៤ សហវ.អថ ចុះថ្ងៃទី២៥/១០/២០១៨
- វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ២០១៩-២០២៣ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់សម្ដេចអគ្គសេនាបតីតេជោ ហ៊ុន សែន ទំព័រទី១-២៤
- គុណភាពគ្រូ ជាគុណភាពមូលធនមនុស្ស សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ៥ តុលា ២០១៨
- សម្ដីលោក រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍កាលពីព្រឹកថ្ងៃទី០៨ខែមករាឆ្នាំ២០១៩ ដោយ សំអឿន កាសែតរស្មីកម្ពុជា
- ប្រកាស៥០៨សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ស្ដីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំយុវជន និងកីឡា
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨
- សៀវភៅមុខវិជ្ជានិងផែនការ បង្រៀនដោយឯកឧត្តមបណ្ឌិត សៀង សុវណ្ណា
- ស្នាដៃនិស្សិតជំនាន់មុន

## ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ [illegible] អយក.វក

ថ្ងៃ [illegible] ខែចេត្រ ឆ្នាំ [illegible] ស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង ៖** កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៥១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីម៉ែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

លេខ : ១១៩ វជអ. ករ

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ារុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទីម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៉ា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វៀរ៉ា | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គីមសាន | ប | ខេត្តកណ្តាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្តាល |
| ២៧ | ស៊ើយ វង្សស៊ុំ | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គីមឈៀន | ប | ខេត្តកណ្តាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គីមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណារ៉ា**

**កន្លែងទទួល៖**

- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

2

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៥/៨៨៤ គេហទំព័រ: www.nie.edu.kh

## ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តត្បូងឃ្មុំ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ

លេខ ១០៤២......ឧទន.រប

**លិខិតឧទ្ទេសនាម**

**យោង** ៖ លិខិតលេខ ១៨៨៥ អយក.វអជ ចុះថ្ងៃព្រហស្បតិ៍ ១៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ។

កញ្ញា **ពេជ្រ រដ្ឋី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ត្រូវបានចាត់ឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំ ។

ថ្ងៃអង្គារ ១០ រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ត្បូងឃ្មុំ ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០១៩

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

អ៊ិន ពៅសម្បត្តិ

**កន្លែងទទួល**

- *ក្រសួងអប់រំ យុវជន និងកីឡា ( វិទ្យាស្ថានជាតិអប់រំ )*
- *ការិយាល័យជំនាញក្រោមឱវាទមន្ទីរ*
- *ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក*
  *"ដើម្បីជូនជ្រាប និងសហការផ្តល់ព័ត៌មាន"*
- *សាមីខ្លួន "ដើម្បីអនុវត្ត"*
- *ឯកសារ.កាវិ.រប*

ឧបសម្ព័ន្ធទី ៣៖ កម្រងសំណួរ

| |
|---|
| **ប្រធានបទ៖ ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀននៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ**<br>Situation of School Operating Fund ( SOF )<br>Implementation in Upper Secondary School<br>in Tbong Khmum Province . |

# កម្រងសំណួរសម្រាប់គណៈកម្មការមូលនិធិដំណើរការសាលារៀន

នាងខ្ញុំឈ្មោះ ពេជ្រ រង្សី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ជំនាន់ទី៦ នឹងធ្វើការសិក្សាស្រាវជ្រាវ លើប្រធានបទ “ **ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន**( SOF )**នៅវិទ្យាល័យក្នុងខេត្តត្បូងឃ្មុំ** ” ដើម្បីបញ្ចប់ ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក លោកស្រី ជាគណៈកម្មការទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការឆ្លើយកម្រងសំណួររបស់នាងខ្ញុំ ។ សូមលោក លោកស្រីទាំងអស់ មេត្តាជួយគូសសញ្ញាសម្គាល់ ឬឆ្លើយសំណួរខាងក្រោម៖

**ផ្នែកទី១៖ ព័ត៌មានអំពីស្ថានភាពទូទៅ**

១.ឈ្មោះ វិទ្យាល័យ...............................................

តួនាទី ☐ ប្រធានគណៈកម្មការ ☐ អនុប្រធានគណៈកម្មការ

☐ ហេរញ្ញិក ☐ តំណាងគ្រូបង្រៀន(សមាជិក)

☐ សហគមន៍ ☐ ប្រធានក្រុមបច្ចេកទេស(សមាជិក)

២.ភេទ ☐ ប្រុស ☐ ស្រី

៣.កម្រិតវប្បធម៌ទូទៅ

☐ បរិ.ជាន់ខ្ពស់ ☐ បរិញ្ញាបត្រ

☐ បរិញ្ញាបត្ររង ☐ សញ្ញាបត្រទុតិយភូមិ ( ជាប់បាក់ឌុប )

☐ ធ្លាក់សញ្ញាបត្រទុតិយភូមិ / ថ្នាក់ទី១២

៤.កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ/មុខរបរ

☐ គ្រូកម្រិតឧត្តម ☐ គ្រូកម្រិតមូលដ្ឋាន

☐ គ្រូចូលនិវត្តន៍ ☐ ប្រជាជន

៥.បទសោធន៍ក្នុងកំឡុងពេលជាគ្រូបការងារ

☐ តិចជាង៣ឆ្នាំ ☐ ៣-៥ឆ្នាំ ☐៦-១០ឆ្នាំ ☐ ១១-១៥ឆ្នាំ

☐ ១៦-២០ឆ្នាំ ☐ ច្រើនជាង២០ឆ្នាំ

☐ ២០ឆ្នាំ ☐ ច្រើនជាង២០ឆ្នាំ

៦.សមត្ថភាពក្នុងការប្រើប្រាស់កុំព្យូទ័រ Words& Excel បាន

☐ ល្អណាស់ ☐ ល្អ ☐ មធ្យម ☐ តិចតួច

៧.ចំណេះដឹងខាងភាសាបរទេស

☐ ភាសាអង់គ្លេស ☐ភាសាបារាំង ☐ភាសាវៀតណាម

**ផ្នែកទី២៖ ស្ថានភាពនៃការអនុវត្តមូលនិធិដំណើរការសាលារៀន**

១.ផែនការអភិវឌ្ឍន៍សាលារៀន ( SDP ) ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ( SOP ) ផែនការថវិកា (SBP) មានលក្ខណៈ

☐ ល្អ ( មានផែនការហើយបានបំពេញគ្រប់ជ្រុងជ្រោយតាមការណែនាំ )

☐ មធ្យម (មានផែនការហើយបានបំពេញមិនបានគ្រប់ជ្រុងជ្រោយតាមការណែនាំ)

☐ មិនល្អ ( មានផែនការ តែមិនអាចយកជាការបាន )

២.កម្រិតនៃការចូលរួមរបស់គណៈគ្រប់គ្រងសាលារៀនក្នុងការធ្វើផែនការផែនការអភិវឌ្ឍន៍សាលារៀន ( SDP ) ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ( SOP ) ផែនការថវិកា(SBP)

☐ គ្រប់ការប្រជុំ

☐ ខកខានម្តងៗ

☐ ពុំសូវបានចូលរួម

៣.កម្រិតនៃការចូលរួមរបស់គណៈកម្មការមូលនិធិដំណើរការសាលារៀនក្នុងការធ្វើផែនការផែនការអភិវឌ្ឍន៍សាលារៀន ( SDP ) ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ( SOP ) ផែនការថវិកា(SBP)

☐ ចូលរួមជាទៀងទាត់តាមផែនការកំណត់

☐ ខកខានមិនបានចូលរួមខ្លះ

☐ ពុំសូវបានចូលរួម

៤.កម្រិតនៃការផ្តល់ធាតុចូលថ្មីៗ(ចែករំលែកចំណេះដឹង ជំនាញ បទពិសោធន៍ )ដែលសំខាន់សម្រាប់ការអភិវឌ្ឍន៍សាលារៀនក្នុងពេលប្រជុំរបស់គណៈកម្មការមូលនិធិដំណើរការសាលារៀន

☐ មានគំនិតល្អៗហើយអាចយកមកអនុវត្ត ទទួលលទ្ធផលល្អ មានផលប៉ះពាល់តិចតួច

☐ មានគំនិតល្អៗហើយអាចយកមកអនុវត្ត ទទួលលទ្ធផលល្អ មានផលប៉ះពាល់ច្រើន

☐ មានគំនិតល្អៗតែពេលយកមកអនុវត្ត មានផលប៉ះពាល់ច្រើន ត្រូវការធនធានច្រើន

៥.កម្រិតនៃការអនុវត្តការងារធ្វើរបាយការណ៍ចំណូល ចំណាយ របាយការណ៍/ឯកសារទូទាត់ និងរបាយការណ៍សមិទ្ធកម្មតាមកាលកំណត់ទៅថ្នាក់ស្រុក មន្ទីរ

☐ បានបំពេញគ្រប់ឯកសារហើយមិនមានកំហុស តាមគោលនិតិវិធីគណនេយ្យ)

☐ បានបំពេញគ្រប់ឯកសារហើយនៅមានកំហុសខ្លះហើយមិនស្របតាមគោលនិតិវិធីគណនេយ្យ

☐ បានបំពេញគ្រប់ឯកសារហើយនៅមានកំហុសច្រើនហើយមិនស្របតាមគោលនិតិវិធីគណនេយ្យ

៦.កម្រិតនៃការអនុវត្តផែនការចុះត្រួតពិនិត្យតាមដានលើឯកសារនិងរបាយការណ៍មូលនិធិដំណើរការសាលារៀន( SOF )

☐ បានអនុវត្តទៀងទាត់រាល់ខែតាមផែនការកំណត់

☐ បានអនុវត្តតែពុំសូវទៀងទាត់រាល់ខែតាមផែនការកំណត់

☐ ពុំសូវបានធ្វើ

៧.កម្រិតនៃការប្រជុំឆ្លុះបញ្ចាំងពីកំហុសនិងវឌ្ឍនភាពនៃការអនុវត្តការងារក្រោយចុះពិនិត្យតាមដាន

☐ ប្រជុំរាល់ពេលធ្វើការពិនិត្យតាមដានរួចក្រោយចុះពិនិត្យតាមដាន

☐ ខកខានមិនបានប្រជុំពេលខ្លះបន្ទាប់ពីធ្វើការពិនិត្យតាមដានរួច

☐ បានប្រជុំភាគតិចបន្ទាប់ពីធ្វើការពិនិត្យតាមដានរួច

៨.កម្រិតនៃការកែលម្អនូវចំណុចខ្វះខាតនានាលើឯកសារក្រោយកិច្ចប្រជុំឆ្លុះបញ្ចាំងលើការចុះពិនិត្យតាមដាន

☐ កែគ្រប់ចំណុចដែលជាកំហុស

☐ បានកែភាគច្រើន

☐ បានកែភាគតិច

៩.កម្រិតនៃការចូលរួមនៃសមាសភាពគណៈកម្មការមូលនិធិដំណើរការសាលារៀនដើម្បីស្វែងរកនូវតម្រូវការជាទិភាពរបស់សិស្ស សាលារៀន និងការកៀរគរធនធានពីអ្នកពាក់ព័ន្ធ

☐ គ្រប់សមាសភាពទាំងអស់

☐ បានចូលរួមភាគច្រើន

☐ បានចូលរួមភាគតិច

១០.ដំណើរការកិច្ចបញ្ជីការគណនេយ្យមូលនិធិដមណើរការសាលារៀនមានលក្ខណៈ

☐ ត្រឹមត្រូវ តាមលេខប្រតិបត្តិការរៀងរាល់ថ្ងៃ

☐ ចុះក្នុងសៀវភៅបេឡាពុំទៀងទាត់រាល់ថ្ងៃ ដាក់លេខប្រតិបត្តិការខ្លះមិនបានខ្លះ

☐ មិនបានចុះលេខប្រតិបត្តិការក្នុងសៀវភៅបេឡា

១១.ការតាមដានសមតុល្យសាច់ប្រាក់ប្រចាំថ្ងៃក្នុងធនាគារនិងសៀវភៅបេឡា

☐ ជាប្រចាំ

☐ បានអនុវត្តតែមិនជាប្រចាំ

☐ មិនបានអនុវត្ត

១២.កម្រិតនៃការទូទាត់ចំណូល ចំណាយ មូលនិធិដំណើរការសាលារៀន( គ.ម.ស ឬ SOF )

☐ បានទាន់ពេលវេលា ហើយត្រឹមត្រូវតាមគោលការណ៍ណែនាំ

☐ យឺតយ៉ាវម្តងម្កាល ហើយត្រឹមត្រូវតាមគោលការណ៍ណែនាំ

☐ មិនទាន់ពេលវេលា ហើយត្រឹមត្រូវតាមគោលការណ៍ណែនាំ

១៣.ឯកសារគាំទ្រសម្រាប់ការទូទាត់មានលក្ខណៈ

☐ មានគ្រប់ឯកសារនិងបានបំពេញគ្រប់ចំណុចពាក់ព័ន្ធទាំងអស់ហើយគ្មានកំហុស

☐ ខ្វះឯកសារខ្លះ បានបំពេញគ្រប់ចំណុចពាក់ព័ន្ធទាំងអស់ហើយគ្មានកំហុស

☐ ឯកសារខ្វះ បានបំពេញគ្រប់ចំណុចពាក់ព័ន្ធទាំងអស់តែមានកំហុសច្រើន

១៤.ការគោរពពេលវេលាបំពេញការងាររបស់គណៈកម្មការ SOF

☐ ទៀងទាត់

☐ មកធ្វើការតែភាគច្រើនមិនចុះហត្ថលេខា

☐ ខកខានខ្លះៗ

១៥.ការប្រជុំប្រឹក្សាយោបល់អំពីការរៀបចំផែនការអភិវឌ្ឍន៍សាលាតែងតែទទួលបានគំនិតថ្មីៗដែលមានលក្ខណៈ

☐ ស្របតាមគោលនយោបាយអប់រំ និន្នាការតំបន់ ពិភពទីផ្សារការងារ

☐ ភាគច្រើនសូវឆ្លើយតបគោលនយោបាយអប់រំ និន្នាការតំបន់ ពិភពទីផ្សារការងារ

☐ ពុំឆ្លើយតបគោលនយោបាយអប់រំ និន្នាការតំបន់ ពិភពទីផ្សារការងារ

១៦.ការបែងចែកធនធានសម្ភារសម្រាប់ដំណើរការបង្រៀន និងរៀន

☐ គ្រប់គ្រាន់ហើយទៀងទាត់ពេលវេលា

☐ គ្រប់គ្រាន់តែមិនសូវទៀងទាត់ពេលវេលា

☐ មិនគ្រប់គ្រាន់ហើយយឺតយ៉ាវ

១៧.ការផ្សព្វផ្សាយជាសាធារណៈនូវផែនការសកម្មភាព ចំណូល ចំណាយ ( SOF )

☐ ទៀងទាត់និងមានតម្លាភាព

☐ ពុំសូវទៀងទាត់និងមានតម្លាភាព

☐ ពុំបានផ្សព្វផ្សាយ

១៨.ការគ្រប់គ្រងហិរញ្ញវត្ថុនិងបែងចែកថវិកាSOF តាមសកម្មភាព មាតិកាចំណាយ មានតម្លាភាព អាចទទួលយកបាន

☐ កម្រិតខ្ពស់

☐ មធ្យម

☐ ក្រោមមធ្យម

១៩.ចំណេះដឹង បទពិសោធន៍ នៃការគ្រប់គ្រងនិងដោះស្រាយបញ្ហារបស់គណៈកម្មការមូល និធិដំណើរការសាលារៀន

☐ កម្រិតខ្ពស់

☐ មធ្យម

☐ ក្រោមមធ្យម

២០.ការរៀបចំផែនការសកម្មភាពមូលនិធិដំណើរការសាលារៀន ( SOF ) មានលក្ខណៈ

☐ ប្រជុំពិភាក្សានិងរៀបចំបែបSMART

☐ ប្រជុំពិភាក្សានិងរៀបចំមិនសូវជាក់លាក់

☐ ផែនការគ្មានលក្ខណៈអាចទទួលយកបាន

ផ្នែកទី៣៖ បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ

១.តើការអនុវត្តSOF ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ?

ចម្លើយ៖.......................................................................................................................

.......................................................................................................................

.......................................................................................................................

២.សូមបញ្ជាក់ពីមូលហេតុដែលធ្វើឱ្យការអនុវត្តមូលនិធិដំណើរការសាលារៀនមានបញ្ហា និងដំណោះស្រាយ

ចម្លើយ.......................................................................................................................

.......................................................................................................................

.......................................................................................................................

៣.សូមរៀបរាប់ពីមូលហេតុដែលមិនអាចដោះស្រាយបញ្ហាក្នុងមូលនិធិដំណើរការសាលារៀន

ចម្លើយ.......................................................................................................................

.......................................................................................................................

៤.តើ SOF មានសារៈប្រយោជន៍អ្វីខ្លះ ? ចូររៀបរាប់ ។

ចម្លើយ.......................................................................................................................

.......................................................................................................................

៥.តើលោក-លោកស្រីមានយុទ្ធសាស្ត្របែបណាខ្លះដើម្បីអភិវឌ្ឍន៍និងបន្តនិរន្តភាពសកម្មភាពសាលារៀន?

ចម្លើយ.......................................................................................................................

.......................................................................................................................

៦.តើលោកលោកស្រីមានសំណូមពរបែបណាចំពោះ

ថ្នាក់ដឹកនាំសាលា.......................................................................................................

.......................................................................................................................

លោកគ្រូ អ្នកគ្រូ.................................................................................................................

..........................................................................................................................................

ថ្នាក់ស្រុក...........................................................................................................................

..........................................................................................................................................

ថ្នាក់មន្ទីរ............................................................................................................................

..........................................................................................................................................

ថ្នាក់ក្រសួង.........................................................................................................................

.............................................................................................................................................

ដៃគូអភិវឌ្ឍន៍.......................................................................................................................

.............................................................................................................................................

សហគមន៍............................................................................................................................

.............................................................................................................................................

មាតាបិតាសិស្ស..................................................................................................................

.............................................................................................................................................

សូមអរគុណ

**ឧបសម្ព័ន្ធទី៤៖**

**១-គណៈកម្មការមេប្រយោគ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** [illegible] **អយក.** [illegible]

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ឌ៉ុយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ងយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២

អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ២-គណៈកម្មការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៩៧២៩ អយក.
(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១០រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ៣-គណៈកម្មការកណ្តាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៩៧៣១ **អយក.** ខស
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង** ៖-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh